អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 27-Jan-2016, 15:50
CMS/CFO: Sann Rada

## កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៦**

**ម៉ោង ១៤:៤១នាទី**

**សវនាការលើកទី៣៦១**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម យ៉ា សុខន

ចៅក្រម ម៉ាទីន ខារ៉ុបគីន
*(Judge Martin KAROPKIN)*

ចៅក្រម ធូ មណី (បម្រុង)

**ក្រឡាបញ្ជីសាលាដំបូង៖**

កញ្ញា ជា ស៊ីវហ៉ង

លោក ម៉ាធូវ ម៉ាកាធី *(Mr.Matthew Mccarthy)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក នីកូឡាស គូមជែន
*(Mr. Nicolas KOUMJIAN)*

លោក ឌេល លីសាក់ *(Mr. Dale Lysak)*

លោក ស្រ៊ា រតនៈ

លោក ចូសេហ្វ អេនឌ្រូ ប៊យលី
*(Mr. Joseph Andrew BOYLE)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក លីវ សុវណ្ណា

លោក វ៉ិចទ័រ កូប៉េ(*Mr.Victor KOPPE*)

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍

*(Mr. Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍(*Ms.Marie GUIRAUD)*

លោក វ៉េន ពៅ

លោក ឡេា ជុនធី

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី ស្វ សុទ្ធាវី

# បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក គង់ សំអុន | ខ្មែរ |
| លោក នីកូឡាស គូមជែន | អង់គ្លេស |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក ឡាច គ្រី (2-TCCP-844) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ឡាច គ្រី** (2-TCCP-844)

សួរបន្តដោយកញ្ញា អង់តា ហ្គីសសេ ផ្តើមពី.................................................................ទំព័រ ១
សួរដោយលោក គង់ សំអុន ផ្តើមពី .........................................................................ទំព័រ ១៥

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[១៤:៤១:០៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយសួស្តីលោក ឡាច គ្រី!

**លោក ឡាច គ្រី៖**

បាទ សួស្តីបងប្រធាន!

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះយើងបន្តធ្វើសវនាកាស្តាប់សក្ខីកម្មរបស់លោកតទៅទៀត ដែលនឹងសួរដេញដោយក្រុមសហមេធាវីការពារក្តីលោក ខៀវ សំផន។ បាទ តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណី ឡាច គ្រី។

**ដោយកញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរបន្តដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ជម្រាបសួរលោក ឡាច គ្រី!

**លោក ឡាច គ្រី**

**ឆ៖** បាទ សូមជម្រាបសួរ!

[១៤:៤២:១៥]

**ស៖** ខ្ញុំសូមបន្តសួរសំណួរកាលពីម្សិលមិញបន្តទៅទៀត។ ឥឡូវនេះ ខ្ញុំសូមនិយាយអំពីឈ្មោះ ជុយ កាលពីម្សិលមិញលោកបានឆ្លើយថា លោកដឹងថា ជុយ ហ្នឹងជាវៀតណាម ដោយសារតែគាត់ហ្នឹងរៀបការជាមួយបងប្អូនជីដូនមួយរបស់លោក។ សូមលោកកុំប្រាប់ឈ្មោះបងប្អូនជីដូនមួយរបស់លោក។ លោកចាំទេ នៅពេលណាដែល ជុយ បានមករស់នៅក្នុងភូមិរបស់លោក?

**ឆ៖** បាទ ជុយ បានរស់នៅក្នុងភូមិពោធិ៍ចិន្តាំរបស់ខ្ញុំបាទហ្នឹង តាំងពីឆ្នាំ១៩៧៥។

**ស៖** លោកប្រាកដទេថា ជុយ មករស់នៅក្នុងភូមិហ្នឹងពីឆ្នាំ៧៥ មិនមែនមុនហ្នឹងទេ?

**ឆ៖** បាទ វា១ចូល៧០ ខ្ញុំបាទចាំមិនសូវច្បាស់ទេ ប៉ុន្តែចូល៧៤ ឬ៧៥ប៉ុណ្ណឹងទេ ដែលខ្ញុំបាទដឹង១ ប៉ុន្តែវាមិនបានចាំថ្ងៃខែឆ្នាំទេ សូមអត់ទោសផង មិនសូវបានចាំខែឆ្នាំ។

**ស៖** ខ្ញុំសួរសំណួរនេះ ពីព្រោះនៅក្នុងសំណុំរឿង យើងមានឯកសារមួយរបស់ឈ្មោះ នៅ សំ តើលោកធ្លាប់ស្គាល់ឈ្មោះ នៅ សំ នេះទេ គាត់រស់នៅភូមិពោធិ៍ចិន្តាំដែរ? សម្រាប់ភាគីទាំងអស់គឺខ្ញុំយោងទៅលើឯកសារ D230/1.1.49b ជាកិច្ចសម្ភាសន៍ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា។--

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ៗលោក!

សូមអញ្ជើញសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

[១៤:៤៥:០៣]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានការកត់សម្គាល់ខ្លីមួយ។ ខ្ញុំមិនជំទាស់នឹងការប្រើប្រាស់ឯកសារនេះទេ ក៏ប៉ុន្តែខ្ញុំសូមរំឭកជូនអង្គជំនុំជម្រះអំពីវិធាននៃការប្រើប្រាស់*អ៊ីនធីហ្វេស*។ អង្គជំនុំជម្រះបានសម្រេចថា ភាគីត្រូវតែដាក់ឯកសារនៅក្នុង*អ៊ីនធីហ្វេស* មួយថ្ងៃមុននៅពេលដែលខ្លួនចង់ប្រើប្រាស់សម្រាប់សួរសាក្សីនោះ។ ក៏ប៉ុន្តែក្នុងចំណោមឯកសារជាង១៥ដែលមេធាវី ខៀវ សំផន បានដាក់ហ្នឹង គឺថាគាត់ដាក់មុនសក្ខីកម្មហ្នឹងតែប៉ុន្មានម៉ោងទេ។ អនុស្សរណៈ៣៤១/១ របស់អង្គជំនុំជម្រះបានបញ្ជាក់ថា ឯកសារដែលត្រូវដាក់នៅក្នុង*អ៊ីនធីហ្វេស*ហ្នឹងគឺត្រូវ២៤ម៉ោង មុនថ្ងៃផ្តល់សក្ខីកម្ម មិនត្រូវមកដាក់ថ្ងៃផ្តល់សក្ខីកម្មភ្លាមៗអ៊ីចឹងទេ។ ខ្ញុំលើកនូវចំណុចនេះឡើង ពីព្រោះថាដូចជាញឹកញាប់ណាស់ទៅហើយដែលមេធាវីការពារក្តីតែងតែធ្វើទង្វើបែបនេះនោះ គាត់តែងតែដាក់នៅនាទីចុងក្រោយ ធ្វើឲ្យយើងទាំងអស់គ្នានេះ នៅពេលដែលយើងចាប់ផ្តើមនោះ យើងអត់អាចអានឯកសារហ្នឹងបាន។ ហើយយើងក៏មិនអាចយកឯកសារនោះមកប្រើប្រាស់សម្រាប់ការសួរដេញដោលរបស់ពួកយើងបាន ប្រសិនបើយើងយល់ឃើញថាមានភាពពាក់ព័ន្ធនោះ។ ខ្ញុំយល់ឃើញថាគោលបំណងនៃការដាក់ក្នុង*អ៊ីនធីហ្វេស*ហ្នឹងគឺដើម្បីគោរពនូវគោលការណ៍ចំពោះមុខ ហើយនិងដើម្បីឲ្យភាគីសហព្រះរាជអាជ្ញា ឬក៏ដើមបណ្តឹងរដ្ឋប្បវេណីមានពេលគ្រប់គ្រាន់ដើម្បីអានឯកសារដែលភាគីផ្សេងបានដាក់ហ្នឹង ហើយអាចជាយថាហេតុ

អាចយកមកប្រើបានសម្រាប់សួរសំណួរទៅកាន់សាក្សី។ ខ្ញុំមិនជំទាស់នឹងការប្រើប្រាស់ឯកសារនេះទេ។ ខ្ញុំគ្រាន់តែចង់ឲ្យភាគីគោរពទៅតាមវិធានដែលអង្គជំនុំជម្រះបានកំណត់ គឺមាននៅក្នុងឯកសារអនុស្សរណៈ E341/1។ សូមអរគុណលោកប្រធាន។

**កញ្ញា អង់តា ហ្គិសសេ៖**

លោកប្រធាន ខ្ញុំសូមឆ្លើយតបដោយខ្លី។ ឯកសារនេះត្រូវបានដាក់កាលពីម្សិលមិញ ដូច្នេះខ្ញុំគិតថាក្នុងឯកសារហ្នឹងវាមានព័ត៌មានសំខាន់សម្រាប់សួរដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។

លោកប្រធាន សំឡេងអ្នកបកប្រែពិបាកស្ដាប់លោកប្រធាន សំឡេងឮមិនច្បាស់ ឮខ្ទរៗ។ លោកប្រធាន ពិបាកស្ដាប់ សំឡេងស្ដាប់មិនបានទេលោកប្រធាន ឮសំឡេងអត់ល្អ។

**ប្រធានអង្គជំនុំ៖**

ផ្អាកៗបន្តិចសិន! មានបញ្ហាបច្ចេកទេសខាងសំឡេង។

*(មានបញ្ហាបច្ចេកទេស)*

[១៤:៤៩:៤២]

**ប្រធានអង្គជំនុំ៖**

បាទ អញ្ជើញៗបន្តទៀត លោកស្រីមេធាវី អង់តា ហ្គិសសេ!

**កញ្ញា អង់តា ហ្គិសសេ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានការឆ្លើយតបខ្លី ខ្ញុំដឹងថាមិនមែនជាការជំទាស់ទេ។ ខ្ញុំសូមជម្រាបថា ចំពោះខាងយើងខ្ញុំ គឺយើងខ្ញុំប្រឹងប្រែងគោរពទៅតាមពេលវេលាដែលកំណត់ដោយអង្គជំនុំជម្រះ ហើយធ្វើយ៉ាងម៉េចផ្ដល់ព័ត៌មានឲ្យភាគីដឹងច្បាស់តាមដែលអាចធ្វើទៅបាន គឺខុសពីដើមបណ្ដឹងរដ្ឋប្បវេណី និងសហព្រះរាជអាជ្ញា គឺថាយើងមានមេធាវីតែមួយ ដែលត្រូវមកសួរសាក្សីផង ត្រៀមៗខ្លួនសម្រាប់សួរសំណួរផង។ អីចឹងយើងនៅក្នុងសវនាការផង ធ្វើការផងអីចឹង យើងពិបាកណាស់។ យើងដឹងថា បើសិនជាដាក់ឯកសារមុនហ្នឹង វាជួយសម្រួលដល់ភាគី ក៏ប៉ុន្តែយើងប្រឹងប្រែងអស់ពីលទ្ធភាពទៅហើយ។ យើងធ្វើតាមលទ្ធភាពដែលយើងអាចធ្វើបាន ដើម្បីគោរពតាមពេលវេលាកំណត់ក្នុងការដាក់ឯកសារមុនពេលថ្ងៃត្រង់ មុនពេលស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះចាប់ផ្ដើមនោះ។--

**ប្រធានអង្គជំនុំ៖**

បាទ ជាបន្តទៅទៀត គ្រាន់តែបន្តទៅបានហើយ មិនបាច់តតាំងអីទៀតទេ។ គ្រាន់តែរំឮកថា នៅពេលក្រោយ គប្បីប្រឹងប្រែងធ្វើយ៉ាងណាឲ្យបានទៅតាមសេចក្ដីណែនាំរបស់អង្គជំនុំជម្រះទៅបានហើយ។

បានហើយ! អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យរំខានការងាររបស់ដំណើរការសវនាការនេះទេ។

អញ្ជើញៗ តាំងសំណួរបន្តទៀត!

[១៤:៥១:៣២]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** លោក ឡាច គ្រី លោកស្ដាប់ខ្ញុំឮទេ?

**លោក ឡាច គ្រី៖**

**ឆ៖** ឮ។

**ស៖** មុននេះខ្ញុំបានសួរលោកថា លោកស្គាល់ឈ្មោះ នៅ សំ ទេ គាត់រស់នៅភូមិពោធិ៍ចិន្ដាំហ្នឹងដែរ?

**ឆ៖** បាទ ខ្ញុំស្គាល់ នៅ សំ រស់នៅក្បែរផ្ទះខ្ញុំដែរ។

**ស៖** នៅក្នុងបទសម្ភាសន៍របស់គាត់ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ខ្ញុំសូមផ្ដល់លេខ ERN ជាភាសាបារាំងគឺ 00848446, ERN ជាភាសាអង់គ្លេស 00822156 និង ERN ជាភាសាខ្មែរគឺ 00451710។ ស្ត្រីរូបនោះ គាត់បាននិយាយអំពីឈ្មោះ ជុយ។ ពេលនោះគេសួរគាត់ថា៖ “ក្នុងឆ្នាំណាដែល ជុយ មកនៅក្នុងភូមិ? គាត់ថា៖ ៧១ ឬ៧២។ ខ្ញុំគិតថា ប្រហែលជា៧១ ដែលគាត់មកនៅហ្នឹង។” លោកដើមបណ្ដឹងរដ្ឋប្បវេណី លោកនឹកឃើញឡើងវិញអំពីពេលដែល ជុយ មកនៅក្នុងភូមិហ្នឹងហើយឬនៅ?

**ឆ៖** បាទ ខ្ញុំបាទ ត្រង់ថា៧១, ៧២ ខ្ញុំបាទអត់ដឹងទេ ប៉ុន្តែដែលខ្ញុំជួបនឹងគាត់នុ៎ង ដែលគាត់ផ្ទាល់ហ្នឹងតែម្ដង គឺថាឆ្នាំ៧៤ ប្រហែលជា៧៤។ ហើយក្រៅពីនុ៎ងៗ ខ្ញុំអត់ដឹងទេ អត់ដឹងថា៧១, ៧២ ខ្ញុំអត់ដឹងៗ។

[១៤:៥៣:៥១]

**ស៖** កាលពីម្សិលមិញ ប្រហែលជាម៉ោង០៣:២៥នាទី ពេលដែលលោកឆ្លើយទៅនឹងមេធាវី

នួន ជា លោកថា លោកមិនដឹងថា ជុយ ហ្នឹងជាទាហានវៀតណាមទេ។ តើលោកមិនចាំ ឬលោកនឹកមិនឃើញ ឬក៏យ៉ាងម៉េច? ហើយនៅក្នុងឯកសារដដែលដែលខ្ញុំបានប្រាប់អម្បាញ់មិញនេះ លេខ ERN ដដែល សាក្សី នៅ សំ ហ្នឹងគាត់បានឆ្លើយថា ខ្ញុំសូមដកស្រង់៖ "ពេលគាត់មកនៅក្នុងភូមិ ជុយ ជាទាហាន"។ បន្ទាប់មកទៀតគេសួរសំណួរគាត់តទៅទៀត៖ "គាត់មកនុ៎ង ជាទាហានឬ? សំ គាត់ឆ្លើយថា៖គាត់នៅធ្វើទាហាន។ ដល់គាត់មកនៅហ្នឹងគាត់ឈប់ធ្វើទាហានហើយ។" សូមបញ្ចប់ការដកស្រង់។ លោក ឡាច គ្រី លោកនឹកឃើញឡើងវិញទេ?

**ប្រធានអង្គជំនុំ៖**

ដើមបណ្តឹងរដ្ឋប្បវេណី កុំអាលទាន់ឆ្លើយតប លោក ឡាច គ្រី!

អញ្ជើញលោកសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក នីកូឡាស គូមជែន៖**

ខ្ញុំគិតថា ប្រហែលជាមេធាវី គាត់កំពុងតែមានចេតនានាំឲ្យដើមបណ្តឹងយល់ខុសហើយ ព្រោះថា ចម្លើយនៅក្នុងមជ្ឈមណ្ឌលឯកសារកម្ពុជាហ្នឹង គេនិយាយអំពីទាហាន។ ប៉ុន្តែការពិតចម្លើយនៅក្នុងមជ្ឈមណ្ឌលឯកសារកម្ពុជា គឺបញ្ជាក់ច្បាស់ថា ជុយ មិនមែនជាទាហានធីវគី ឬក៏មិនមែនជាទាហានវៀតកុងទៀត គឺថាគាត់មកពីភ្នំពេញទេ ហើយគាត់និយាយខ្មែរច្បាស់ល្អណាស់ ដោយមិនមានតុងយួនអ្វីឡើយ។ ដូច្នេះហើយមេធាវីគាត់ថា ជុយ ជាវៀតណាម ហើយសាក្សីក៏គាត់ថាវៀតណាម។ ដូច្នេះការធ្វើអ៊ីចឹង ជាការនាំឲ្យសាក្សីយល់ខុស។

[១៤:៥៦:០៨]

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំប្រហែលជាអានកន្លែងខុសគ្នា នៅក្នុងឯកសារនេះ។ ក៏ប៉ុន្តែជាទូទៅហ្នឹង គឺថានៅក្នុងឯកសារហ្នឹង នៅក្នុងទំព័រដែលខ្ញុំអានហ្នឹង គេសួរគាត់ថា តើទាហានហ្នឹងទាហានធីវគី ឬក៏ទាហានវៀតកុង? គាត់ថា មិនមែនទាហានទាំងពីរទេ ហើយគាត់មិនដឹងទាហានមកពីខាងណាទេ។ អ៊ីចឹងក្នុងនេះគឺគាត់ដឹងថា ជុយ ហ្នឹងជាទាហាន ក៏ប៉ុន្តែមិនដឹងទាហានខាងណា។ ដូច្នេះអ្វីដែលសហព្រះរាជអាជ្ញាលើកឡើងហ្នឹង ក៏មិនមានបញ្ជាក់នៅក្នុងបទសម្ភាសន៍នេះដែរ។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ប៉ុន្តែទោះជាយ៉ាងណាក៏ដោយលោក ឡាច គ្រី សំណួរខ្ញុំនោះ ខ្ញុំចង់ដឹងថា តើលោកមាន

បាននិយាយគ្នាជាមួយ ជុយ ថា ហើយគាត់មានបានប្រាប់លោកថា តើគាត់ជាទាហាន ឬក៏អត់ទេ?

**លោក ឡាច គ្រី៖**

**ឆ៖** បាទ លោកមេធាវី ខ្ញុំអត់ដឹង អត់បាននិយាយ ហើយមិនដឹងថា ជុយ ហ្នឹងទាហាន ឬមិនទាហាន ប៉ុន្តែឃើញមកនៅភូមិពោធិ៍ចិន្តាំហ្នឹង គាត់ជាប្រជាជនធម្មតា។

[១៤:៥៧:៣១]

**ស៖** នៅក្នុងសំណុំរឿង សុំលោកកុំប្រាប់ឈ្មោះបងប្អូនជីដូនមួយរបស់លោក។ យើងមានឯកសារមួយនៅក្នុងសំណុំរឿងគឺ2-TCCP-896 ឯកសារE3/7809 ERNជាភាសាបារាំង 00486104, ERN ជាភាសាអង់គ្លេស 00282563, ERN ជាភាសាខ្មែរគឺ 00271368។ នេះជាចម្លើយរបស់បងប្អូនជីដូនមួយរបស់លោក។ “ខ្ញុំមិនឮការប្រកាសជាផ្លូវការអីទេ។” នៅពេលនុំងគេសួរសំណួរគាត់៖ “នៅឆ្នាំ៧៥ តើលោកស្រីដឹងអ្វីខ្លះពីគ្រួសារវៀតណាម? ខ្ញុំអត់មានឮការប្រកាសជាផ្លូវការអីទេ ប៉ុន្តែប្ដីខ្ញុំ ខ្ញុំខ្លួនឯងផ្ទាល់ ក៏ដូចជាអ្នកភូមិបានដឹងថា វៀតណាមត្រូវតែត្រឡប់ទៅស្រុកវិញ ទៅវៀតណាមវិញ។ ប្ដីខ្ញុំមិនព្រមទៅទេ គាត់ចង់នៅជាមួយប្រពន្ធកូន។ តាមពិតទៅខ្ញុំក៏ចង់ទៅវៀតណាមដែរ។” ហើយនៅពេលនោះគាត់បញ្ជាក់ទៀតថា គាត់ជាអតីតទាហានវៀតណាម ប្ដីគាត់ហ្នឹងដែលបានបែកចេញពីទ័ព ហើយមកធ្វើ មករកស៊ី មកនៅភូមិពោធិ៍ចិន្តាំ ហើយរត់ចេញពីទ័ពមក។ សូមបញ្ចប់ការដកស្រង់។ លោក ឡាច គ្រី បងប្អូនជីដូនមួយស្រីរបស់លោក បានបញ្ជាក់ថា ប្ដីរបស់គាត់ជាអតីតទាហានវៀតណាមដែលបានបាក់ទ័ព ហើយរត់មកនៅក្នុងភូមិពោធិ៍ចិន្តាំ។ ដូច្នេះលោកធ្លាប់និយាយជាមួយបងប្អូនជីដូនមួយរបស់លោក ឬក៏ជាមួយ ជុយ អំពីបញ្ហាទាំងអស់ហ្នឹងទេ?

**ឆ៖** បាទ ខ្ញុំមិនដែលនិយាយទេ អត់ដែលនិយាយ ហើយមិនដឹងថា ជុយ ហ្នឹងជាទាហាន ឬមួយអីទេ ខ្ញុំអត់ដឹង។ ដឹងថាគាត់ជាប្រជាជនធម្មតា អត់ដឹង ហើយឈ្មោះ ដួង អឿន ហ្នឹងទៀត ជាបងប្អូនជីដូនមួយរបស់ខ្ញុំបាទហ្នឹង ក៏មិនដែលនិយាយប្រាប់រឿងថាប្ដីជាទាហាន ឬជាស្អីទេ មិនមានដែលនិយាយផង។

**ស៖** ដើម្បីឲ្យច្បាស់ គឺប្រហែលជាមានបញ្ហាពាក់ព័ន្ធនឹងការបកប្រែ។ លោកឆ្លើយថា លោកមិនដែលបានពិភាក្សា ឬក៏សំណេះសំណាលអីជាមួយ ជុយ ទេ មែនទេ អំពីបញ្ហាហ្នឹង?

[១៥:០១:០៤]

**ឆ៖** បាទ មែន។

**ស៖** ពេល ជុយ មកនៅក្នុងភូមិរបស់លោកហ្នឹង គឺប្រពន្ធរបស់គាត់បាននិយាយថា ពួកគាត់ហ្នឹងរកស៊ីលក់ដូរ។ ដូច្នេះខ្ញុំចង់ដឹងថា តើមុខរបរពិតប្រាកដហ្នឹងធ្វើអីដែរ? គាត់លក់ដូរហ្នឹង លក់ដូរអីគេដែរ លោកនៅចាំទេ?

**ឆ៖** បាទ ពេលដែលខ្ញុំជួបគាត់ហ្នឹង ពេលហ្នឹងគាត់លក់ដូរ ជួនកាលត្រីទៅ ហើយប្រពន្ធលក់បន្លែ លក់នំ ប្រពន្ធរបស់គាត់ហ្នឹង ជីវភាពគាត់រស់នៅហ្នឹង។ បាទ តែប៉ុណ្ណឹងទេ ដែលខ្ញុំបាទដឹង។

**ស៖** នៅពេលឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា បងប្អូនជីដូនមួយរបស់លោកនោះ គាត់បានឆ្លើយ ហើយខ្ញុំមានតែឯកសារហ្នឹងមានតែជាភាសាអង់គ្លេស អ៊ីចឹងខ្ញុំសូមអានជាអង់គ្លេស។ គឺឯកសារ E3/7562, ERN ជាភាសាអង់គ្លេសគឺ 01157781, ERN ជាភាសាខ្មែរ 00034081។ គេសួរគាត់នៅពេលនោះ ខ្ញុំសូមអភ័យទោស ខ្ញុំសូមអានជាភាសាអង់គ្លេសនូវចម្លើយរបស់បងប្អូនជីដូនមួយរបស់លោក។ “តើលោកប្រាប់យើងបានទេ ថាតើប្ដីរបស់លោកស្រីធ្វើអ្វីនៅពេលនោះ? ចម្លើយ៖ គាត់មិនធ្វើការអីទេ។ នៅពេលនោះគាត់អាចចាកចេញ ចេញចូលប្រទេសខ្មែរបាន ហើយគាត់ជាអ្នកលក់ដូរ។ សំណួរ៖ ពិតទេ? ចម្លើយ៖ ចាស។ នៅពេលនោះគាត់ចេញចូលប្រទេសខ្មែរ គាត់អត់មានការងារអ្វីផ្សេងទេ។ គាត់នៅផ្ទះ ហើយគាត់ធ្វើខ្ពុយ ហើយប្រជាជនមកទិញពីគាត់ នាំទៅវៀតណាម។ តើគេមកទិញច្រើនទេ? បាទ គាត់មិនមានការងារអីផ្សេងទេ។ តើគាត់លក់ដូរអ្វីនៅពេលនោះ? គាត់មិនមានលុយច្រើនទេនៅពេលនោះ។ យួនចូលមកប្រទេសខ្មែរយ៉ាងច្រើន ហើយមកទិញអីវ៉ាន់ពីគាត់។ តើគាត់មានលុយច្រើនទេ? ចាស គាត់មានលុយច្រើន។” សូមបញ្ចប់ការដកស្រង់។ លោក ឡាច គ្រី ក្រោយពីខ្ញុំអានចម្លើយអម្បាញ់មិញនេះ លោកនឹកឃើញទេថា ជុយ ហ្នឹងគាត់លក់កញ្ឆានៅក្នុងភូមិរបស់លោក?

[១៥:០៥:០៦]

**ឆ៖** បាទ ចំពោះ ជុយ ហ្នឹង ខ្ញុំមិនបានដឹងលក់អីៗ មិនបានដឹងទេ ប៉ុន្តែខ្ញុំធ្លាប់ឃើញគាត់នេះលក់ៗត្រី ជួនកាលលក់ត្រី ប្រពន្ធលក់នំទៅ។ ហើយក្រៅពីនោះទៀត ខ្ញុំបាទអត់ៗបានដឹង មិនដឹងជាលក់ស្អី ព្រោះផ្ទះនៅឆ្ងាយពីគ្នាដែរ។

**ស៖** សូមអរគុណ។ ទោះបីជាលោកមិនបានដឹងថាតើគាត់ធ្វើអីពិតប្រាកដក៏ដោយ តើលោកអាចបញ្ជាក់បានទេ នៅក្នុងចម្លើយរបស់សាក្សីអម្បាញ់មិញនេះ គាត់ថាឈ្មោះ ជុយ ហ្នឹងគឺថាមានលុយច្រើន ហើយរស់នៅធូរធារស្រួល តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ ខ្ញុំមើលពិនិត្យគាត់ ដែលធ្លាប់ជួបគ្នាម្ដងៗ យូរៗម្ដងទៅ គាត់ហ្នឹងមិនមែនជាអ្នកមាន

ទេ អ្នកក្រៗបាទ។ ប្រពន្ធគាត់ហ្នឹងក្រជាទីបំផុត ផ្ទះតូច តៀមតូចមួយ ហើយ ជុយ ហ្នឹងទៅនៅផ្ទះ តៀមហ្នឹង ក៏ជាមួយប្រពន្ធហ្នឹង ក៏ផ្ទះតូចដែរ។ ដូចគ្មានអីឲ្យគួរកត់សម្គាល់ថាគាត់អ្នកមានទេ គឺអត់ៗ កត់សម្គាល់ឃើញ។ ខ្ញុំបាទធ្លាប់ឃើញគាត់អ៊ីចឹង។

**ស៖** ឥឡូវនេះ ខ្ញុំសូមចូលទៅប្រធានបទមួយផ្សេងទៀត។ ខ្ញុំសូមនិយាយអំពីពេលមុនឆ្នាំ៧៥ ជាពិសេសគឺឆ្នាំ៧០ ពេល លន់ នល់ធ្វើរដ្ឋប្រហារ។ លោកចាំទេថានៅពេលនោះមានជនជាតិវៀតណាម វិលត្រឡប់ទៅវៀតណាមវិញទេ? គេមានរៀបចំឲ្យវៀតណាមធ្វើមាតុភូមិនិវត្តន៍ទៅវៀតណាមវិញទេ? លោកនឹកឃើញអំពីហេតុការណ៍ហ្នឹងទេ?

**ឆ៖** បាទ ខ្ញុំធ្លាប់នៅក្នុងភូមិហ្នឹង ព្រឹត្តិការណ៍ដែលកើតឡើងពីឆ្នាំ៧០ហ្នឹង គឺថាវៀតណាម ជំនាន់ហ្នឹង គឺវិលត្រឡប់ទៅប្រទេសវៀតណាមវិញ ជាបន្តបន្ទាប់។ បាទជំនាន់នុ៎ង វាមានវៀតណាមខ្លះ ក៏នៅ វៀតណាមខ្លះក៏ទៅ ប៉ុន្តែភាគច្រើនទៅ នៅតិចណាស់។ នៅភូមិរបស់ខ្ញុំបាទហ្នឹង នៅតែបីគ្រួសារ ទេ បីគ្រួសារដូចខ្ញុំជម្រាប ឡាច នី ហ្នឹងទេ។ នៅតែបីគ្រួសារហ្នឹងទេដែលនៅ ក្រៅពីហ្នឹងអត់មានទេ ទៅអស់រលីង។

[១៥:០៨:១៧]

**ស៖** លោកនិយាយអំពីស្ថានភាពនៅក្នុងភូមិរបស់លោក ក៏ប៉ុន្តែខ្ញុំសួរលោកហ្នឹង ខ្ញុំចង់ដឹងថា លោកចាំទេ គឺក្រោយពីរដ្ឋប្រហារ លន់ នល់ ហើយនោះ មិនសំដៅតែភូមិរបស់លោកទេ គឺជាទូទៅតែ ម្តង គឺលោកមានតាមដានព្រឹត្តិការណ៍ពេលហ្នឹងទេ មានស្តាប់វិទ្យុ មានអានកាសែត មានដឹងថា ក្រៅពី នៅភូមិរបស់លោកហ្នឹង នៅកន្លែងផ្សេងៗទៀតហ្នឹង មានការបញ្ជូនវៀតណាមទៅឲ្យ ទៅៗប្រទេស វៀតណាមវិញទេ? នៅទូទាំងប្រទេស ខ្ញុំមិនសំដៅតែលើភូមិលោកទេ។

**ឆ៖** បាទ លោកមេធាវី ពេលនោះគឺថាវៀតណាម គឺថាគាត់ ឆ្នាំ៧០ហ្នឹងគឺគាត់ចេះតែទៅ ប្រទេសវៀតណាមវិញបណ្តើរៗ តាមក្នុងឃុំរបស់ខ្ញុំបាទហ្នឹង។ ហើយទូទាំងប្រទេស ក៏ច្រើនចេញ ទៅដែរ ទៅបណ្តើរៗ ទៅចេះតែទៅប្រទេសវៀតណាមវិញ។ ហើយមិនសូវមាននៅទេ ពី៧០មក ទាល់៧៥ហ្នឹង អត់សូវមានទេ គឺថាគាត់ទៅប្រទេសវៀតណាមវិញ។ នៅខ្លះ នៅតែអ្នកដែលមាន គ្រួសារខ្មែរ ឬមួយមានគ្រួសារវៀតណាមហ្នឹង អាហ្នឹងមាននៅ។

**ស៖** បាទ សូមអរគុណ។ ក៏ប៉ុន្តែខ្ញុំចង់ដឹងឲ្យច្បាស់តែម្តង លោកថា វៀតណាមត្រឡប់ទៅវិញ មួយម្តងៗ ប៉ុន្តែខ្ញុំចង់ដឹងពីពេលដែលរដ្ឋប្រហារហើយភ្លាមនោះ គេមានបញ្ជូនវៀតណាមទាំងអស់ឲ្យ

ទៅស្រុកវិញទេ? បើលោកមិនចាំទេ មិនអីទេ ខ្ញុំគ្រាន់តែសួរថាលោកចាំ ឬមិនចាំ លោកមិនចាំ លោកឆ្លើយថាមិនចាំទៅ មិនជាបញ្ហាអ្វីទេ។

[១៥:១០:១៧]

**ឆ៖** បាទ ពីព្រោះខ្ញុំចាំតែមូលដ្ឋានរបស់ខ្ញុំបាទទេ ដល់អ្នកដល់ក្រៅនោះអត់ចាំទេបាទ អត់ចាំទេ ហើយបើតាមតែមូលដ្ឋានខ្ញុំបាទ ដឹង ដល់ខុសពីមូលដ្ឋានខ្ញុំបាទ អត់ដឹង។

**ស៖** ឥឡូវនេះ ខ្ញុំសូមចូលទៅប្រធានបទមួយទៀត។ លោកបាននិយាយថា មានការទទួលយ៉ាងកក់ក្ដៅចំពោះបងថ្លៃរបស់លោក ពេលដែលបងប្រុសរបស់លោកណែនាំប្រពន្ធគាត់ឲ្យស្គាល់ហ្នឹង ថាអ្នកនៅក្នុងគ្រួសារហ្នឹង គេទទួលយ៉ាងកក់ក្ដៅចំពោះវត្តមានបងថ្លៃរបស់លោក។ ហើយលោកថាមិនមានបញ្ហាអ្វីរវាងខ្មែរ និងវៀតណាមទេនៅពេលហ្នឹងនោះ។ ដូច្នេះ ខ្ញុំចង់សួរលោកដូចតទៅ ទោះបីជាមិនមានបញ្ហាអ្វីក៏ដោយ តើពេលខ្លះទៅអាចមានបញ្ហាមិនយល់គ្នា មានបញ្ហាបុរេវិនិច្ឆ័យអ្វីពាក់ព័ន្ធទៅនឹងជនជាតិវៀតណាមទេ? ខ្ញុំសួរតែអ្វីដែលលោកដឹងតែប៉ុណ្ណោះ។

**ឆ៖** ក្នុងពេលដែលខ្ញុំបាទបានជួបប្រាស្រ័យទាក់ទងជាមួយខ្ញុំបាទជាប្អូនហ្នឹង បាតុភាពដែលកើតឡើងហ្នឹង គឺគ្មានសោះ ចំពោះបងថ្លៃរបស់ខ្ញុំបាទហ្នឹងអត់មានទេ។ វៀតណាមនៅ គាត់ជាវៀត-ណាមមែន ប៉ុន្តែអត់មានបញ្ហាជាមួយអ្នកដទៃ ឬមួយអ្នកណាទេ ធម្មតាដូចយើងជនជាតិខ្មែរដែរ។ អត់មានជម្លោះទាស់ទែងបងប្អូនណា ឬមួយមានបាតុភាពអ្វីធ្វើឲ្យទំនាស់ដល់អ្នកជិតខាងទេ គឺថាធម្មតា។

**ស៖** ប្រហែលជាសំណួរខ្ញុំមិនសូវច្បាស់មើលទៅ។ អ្វីដែលខ្ញុំចង់ដឹងនោះគឺថាក្រៅពីទំនាក់ទំនងផ្ទាល់ខ្លួននោះ ក្នុងភូមិនុំងមានអ្នកណាគេមានបុរេវិនិច្ឆ័យ មានន័យថាឲ្យតែឃើញវៀតណាមគេស្អប់គេអីអ៊ីចឹង មានទេនៅក្នុងភូមិហ្នឹង?

[១៥:១២:៥៦]

**ឆ៖** បាទ មេធាវី ខ្ញុំឃើញគាត់ហ្នឹងគឺថាគ្មានគេស្អប់ទេ ពីព្រោះគាត់ជាអ្នកប្រជាប្រិយមួយល្អគ្មានអ្នកណាគេស្អប់ គេរាប់អានគាត់ធម្មតាដូចបងដូចប្អូនដែរ អត់មានអ្នកណាទំនាស់នឹងគាត់ ឬស្អប់ខ្ពើមគាត់ទេ។

**ស៖** ប្រហែលជាលោកមិនយល់សំណួរខ្ញុំ។ ខ្ញុំមិននិយាយអំពីបងថ្លៃរបស់លោកទេ ខ្ញុំនិយាយអំពីវៀតណាមជាទូទៅ ជនជាតិវៀតណាមជាទូទៅនៅក្នុងភូមិរបស់លោកហ្នឹង។ លោកធ្លាប់ឮប្រជាជនខ្មែរហ្នឹងនិយាយគ្នា ជជែកគ្នាដែលបង្ហាញពីការស្អប់ខ្ពើម ឬក៏បង្ហាញថាខ្លួនមិនពេញចិត្តជនជាតិ

វៀតណាមអីអ៊ីចឹង មានទេ?

**ឆ៖** បាទ លោកមេធាវី អត់មានទេ។ អត់ដែលខ្ញុំឮទេ អត់ដែលឮ ខ្ញុំអត់ដែលឮ។

**ស៖** លោកធ្លាប់ឮគេនិយាយថា វៀតណាមមានអត្តចរិតមិនដូចខ្មែរអីអ៊ីចឹង លោកឮគេនិយាយទេថា មានឥរិយាបថខុសពីខ្មែរដែលធ្វើឲ្យខ្មែរទើសចិត្ត មិនពេញចិត្តអីអ៊ីចឹង មានធ្លាប់ឮគេនិយាយអ៊ីចឹងទេ?

**ឆ៖** បាទ ខ្ញុំមិនដែលឮនិយាយផង អត់ធ្លាប់ឮនិយាយអ៊ីចឹងតែម្តង។

[១៥:១៤:៣៦]

**ស៖** ខ្ញុំសួរសំណួរនេះ ពីព្រោះថាក្នុងបទសម្ភាសន៍ដែលលោកបានផ្តល់ជូនមជ្ឈមណ្ឌលឯកសារកម្ពុជា គឺឯកសារ E3/5640, ERN ជាភាសាបារាំង 00657815, ERN ជាភាសាខ្មែរគឺ 00034400 និងERN ជាភាសាអង់គ្លេស00645400។ លោកបាននិយាយជាមួយអ្នកសម្ភាសលោកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា លោកនិយាយថា មានការទទួលស្វាគមន៍បងថ្លៃរបស់លោកយ៉ាងកក់ក្តៅ ពេលនោះអ្នកសម្ភាសន៍គេសួរលោកថា៖ "ហេតុអ្វីបានជាគេមិនប្រកាន់គាត់អ៊ីចឹង? (តាមពិតទៅគេចង់ថាហេតុអីបានជាឪពុកម្តាយរបស់លោកមិនបានបន្ទោសបងប្រុសលោកថារៀបការជាមួយយួនអ៊ីចឹង) ហើយពេលនុ៎ងលោកឆ្លើយថា៖ មិនប្រកាន់ ព្រោះថាកូនហ្នឹងដូចជាខ្មែរដែរ យួន វៀតណាមដូចតែខ្មែរ ប៉ុន្តែវៀតណាមនៅប្រទេសវៀតណាមឯណា វៀតណាមស្រុកកំណើតគាត់នៅបាត់ដំបង កាលហ្នឹងគឺពីសង្គមគាត់នៅបាត់ដំបង។ គេមិនបន្ទោសអីថាយកប្រពន្ធអីវៀតណាមទេ ពេលនុ៎ង។ តើលោកដើមបណ្តឹងរដ្ឋប្បវេណីលោកថាបងថ្លៃលោកហ្នឹងមិនដូចវៀតណាមផ្សេងទេ គឺថាគាត់មានចរិតអីដូចខ្មែរ។ ដូច្នេះលោកចង់មានន័យថាម៉េច ថាបងថ្លៃលោកហ្នឹងមិនដូចវៀតណាមផ្សេងទៀតទេ គឺគាត់មានចរិតដូចខ្មែរនោះ?

**ឆ៖** បាទ លោកមេធាវី ដែលខ្ញុំបាទថាឲ្យគាត់ចរិតដូចខ្មែរ ពីព្រោះគាត់ហ្នឹង គ្រាន់តែនិយាយភាសារាងរដឹនបន្តិចទៅខាងវៀតណាមបន្តិច សម្តីហ្នឹង។ ប៉ុន្តែក្នុងការអត្តចរិតរបស់គាត់ហ្នឹង គឺដូចខ្មែរអ៊ីចឹង ក្នុងការលក់ដូរក៏ដោយ ក្នុងការនិយាយស្តីក៏ដោយដូចខ្មែរអ៊ីចឹង គឺគ្មានធ្វើឲ្យអ្នកជទៃចាប់អារម្មណ៍ថាគាត់ហ្នឹងជាវៀតណាមទេ ដូចខ្មែរអ៊ីចឹង ពីព្រោះឪពុកគាត់ហ្នឹងខ្មែរ ម្តាយវៀតណាម។ គាត់អ៊ីចឹង។ ហើយដល់បងខ្ញុំទៅយកប្រពន្ធហ្នឹង ទៅយកហ្នឹង គឺគាត់យកមិនមែនដោយការអីត្រឹមត្រូវទេ គឺថាក្នុងការលួចលាក់ជំនាន់នុ៎ង ពីសង្គមរាស្ត្រនិយម ជំនាន់សង្គមរាស្ត្រនិយមនោះ។ ទៅយក គឺថាដោយចិត្តនឹងចិត្ត។ ហើយបានគាត់ស្រឡាញ់គ្នាហ្នឹង បានគាត់នាំទៅនៅស្រុកហ្នឹង។ បាទ សូមជម្រាបប៉ុណ្ណឹង។

[១៥:១៨:០៩]

**សះ** ខ្ញុំសួរសំណួរនេះ ពីព្រោះថានៅក្នុងសម្រង់ដែលខ្ញុំបានអាននោះ លោកមិនបាននិយាយអំពីតុងសំឡេងរបស់គាត់ទេ លោកនិយាយអំពីចរិត ហើយនិងឫកពារគាត់។ លោកថាចរិត ឫកពារហ្នឹងគឺដូចខ្មែរ មិនដូចវៀតណាមផ្សេងទៀតទេ គាត់ដូច គឺគាត់មានចរិតដូចខ្មែរតែម្ដង។ អ៊ីចឹងកន្លែងនេះខ្ញុំចង់ដឹងលោកមានន័យថាម៉េច កន្លែងហ្នឹង?

**ឆះ** បាទ បានខ្ញុំដឹង ថាព្រោះគាត់ហ្នឹងថាក្នុងទំនាក់ទំនងជាមួយខ្មែរ និយាយលេងជាមួយខ្មែរអីសព្វបែបសព្វយ៉ាងហ្នឹង គឺថាជាមួយនឹងខ្មែរគ្នា បងប្អូនខ្មែរដែលនៅជិតៗគាត់ហ្នឹង គឺថាគាត់ដូចខ្មែរដែរចរិតគាត់។ ចរិតគាត់ ចរិតខ្ញុំហ្នឹង ចរិតក្នុងការនិយាយស្ដីសព្វបែបសព្វយ៉ាងហ្នឹង គាត់មិនចេះប្រកាន់វណ្ណៈ ថាគាត់អីចេះអីចុះ ជាជនជាតិដទៃ ឬមួយសាសន៍ដទៃអត់មានទេ ដូចខ្មែរយើងអ៊ីចឹង។ ហើយការដែលគាត់មករស់នៅក្នុងភូមិរបស់ខ្ញុំបាទហ្នឹង តាំងឡាច នី ហ្នឹងក៏ដោយ ប្រពន្ធគាត់ក៏ដោយ គឺម្ដាយឪពុកខ្ញុំក៏ស្រឡាញ់គាត់ដែរ ស្រឡាញ់ដូចខ្មែរដែរ។

**សះ** ខ្ញុំយល់អំពីចម្លើយរបស់លោកត្រង់ចំណុចនេះ ខ្ញុំយល់ច្បាស់ហើយ។ ខ្ញុំព្យាយាមសួរលោកចុងក្រោយម្ដងទៀត។ តាមរយៈចម្លើយរបស់លោកដែលខ្ញុំបានអានឲ្យលោកស្ដាប់នេះ មុនពេលលោកស្គាល់បងថ្លៃលោក លោកផ្ទាល់ ឬក៏ក្រុមគ្រួសារលោកហ្នឹងមានការយល់ឃើញយ៉ាងម៉េចពីស្ត្រីវៀត-ណាមដែរពេលនុ៎ង?

[១៥:២០:០៦]

**ឆះ** បាទ ពេលដែលគាត់នាំពីភ្នំពេញទៅនៅស្រុកកំណើតរបស់ខ្ញុំបាទហ្នឹង គឺប្ដីរបស់គាត់ឡាច នី ហ្នឹង គាត់អ្នកប្រាប់ថា ខ្ញុំយកគ្រួសារវៀតណាម។ ប្ដីឆ្លើយប្រាប់ ប្រាប់ចំពោះមាតាបិតារបស់ខ្ញុំហ្នឹង និងបងប្អូន អ្នកជិតខាងទាំងអស់គ្នាអ៊ីចឹងដែរ។ បានខ្ញុំសន្និដ្ឋានគាត់ហ្នឹងថា ជាវៀតណាម។ ហើយនិយាយភាសាហ្នឹង ក៏មិនជាច្បាស់អីដូចខ្មែរដែរ វារាងប៉ៃឡាំដូចវៀតណាមដែរ រាងប៉ៃឡា បែបប៉ៃឡាំតិចៗ។

**សះ** ខ្ញុំនឹងមិនជជីកសួរអ្វីទៅលើចំណុចនេះទៀតទេ។ ខ្ញុំសូមចូលទៅប្រធានបទចុងក្រោយរបស់ខ្ញុំ។ លោកប្រធាន មេធាវី គង់ សំអុន ក៏មានសំណួរសួរផងដែរ ក្រោយពីខ្ញុំទៅ។ ហើយឥឡូវនេះ ខ្ញុំចង់សួរអំពីខ្សែជីវិតរបស់បងប្រុសរបស់លោក។ លោកថា គាត់ធ្លាប់មកធ្វើការនៅភ្នំពេញ ហើយក្រោយមកត្រឡប់ទៅភូមិវិញ ដោយនាំទាំងប្រពន្ធវៀតណាមទៅផង។ ដូច្នេះខ្ញុំចង់ដឹង ក្នុងមួយជីវិតរបស់គាត់

នោះ គាត់ធ្លាប់ធ្វើការនៅប្រទេសក្រៅទេ? ក្រៅពីកម្ពុជា គាត់ធ្លាប់ទៅបរទេសទេ?

**ឆ៖** បាទ លោកមេធាវី កាលពីគាត់មិនទាន់មានប្រពន្ធហ្នឹង ក៏បានរៀនសូត្រ ចេះដឹងខ្ពង់ខ្ពស់ បាទខ្ពង់ខ្ពស់ណាស់។ ហើយគាត់នោះបានទៅរៀនទៅដល់នៅប្រទេសអាល្លឺម៉ង់ បានទៅមួយៗវគ្គ បានទាល់រៀន ឬមិនរៀន ខ្ញុំបាទអត់បានដឹងទេ។ ប៉ុន្តែគាត់ទៅប្រទេសអាល្លឺម៉ង់ហើយ គាត់ត្រឡប់មកវិញ។ ត្រឡប់មកវិញ មករកការងារធ្វើនៅភ្នំពេញហ្នឹង។ បើធ្វើការងារភ្នំពេញ ខ្ញុំបាទមិនបានដឹងស្គាល់ថា គាត់ហ្នឹងធ្វើការអី ឬធ្វើការអីដែរ អត់ដឹងទេ។ ដល់ក្រោយមក ឆ្នាំ១៩៦៨ គាត់មានប្រពន្ធហ្នឹង គាត់នាំទៅស្រុក ប៉ុន្តែគាត់ហ្នឹងខ្លាច នី នឹងគាត់ចេះៗភាសាច្រើន ដែលខ្ញុំបាទដឹងហ្នឹង។ គាត់បើនិយាយទៅ វាជាប់ក្នុងសាស្ត្រាចារ្យផង បើតាមខ្ញុំបាទដឹងតិចៗ។ បើខ្ញុំវាអ្នកនៅក្មេង វាមិនសូវដឹង មិនសូវយល់ការ។ គាត់ហ្នឹងចេះភាសា*(ឮមិនច្បាស់)*មុខ ឡាច នី ហ្នឹង។ ទី១ វៀតណាម, ទី២ បារាំង, ទី៣ អង់គ្លេស ហើយអាល្លឺម៉ង់ហ្នឹង។ បាទ ចេះច្បាស់ ខ្ញុំសួរគាត់ច្បាស់។ ហើយក្រោយមកទៀត គឺខ្ញុំបាទក្នុងការគាត់ឈប់ពីការងារអ្វីផ្សេងៗ គឺខ្ញុំបាទអត់ដឹងទេ ពីព្រោះខ្ញុំវានៅក្មេងដែរ។ ខ្ញុំដឹងតែប៉ុណ្ណឹងទេ។

[១៥:២៣:២៣]

**ស៖** លោកដឹងថា គាត់ចេះនិយាយភាសាចិនទេ?

**ឆ៖** បាទ ភាសាចិនចេះ ប៉ុន្តែចេះមួយម៉ាត់ៗទេ មិនសូវជាចេះច្រើនទេ ចេះតិចៗទេ។ ចេះយួរទៅ ស្តាប់បានមួយម៉ាត់ៗ ប៉ុណ្ណឹងទេបាទ។

**ស៖** ក្រៅពីភាសាអាល្លឺម៉ង់ -- ក្រៅពីប្រទេសអាល្លឺម៉ង់ គាត់ធ្លាប់ទៅប្រទេសណាផ្សេងទៀតទេ?

**ឆ៖** បាទ ដែលខ្ញុំធ្លាប់ដឹង គឺថាគាត់ទៅ--

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ៗឆ្លើយ!

លោកស្រីមេធាវីអាចបញ្ជាក់បានទេ វាពាក់ព័ន្ធជាមួយនឹងអង្គហេតុដែលយើងធ្វើសវនាការហ្នឹងយ៉ាងដូចម្តេចទៅ? លើកសួរនូវអំពីបញ្ហា ឡាច នី ចេះភាសាអីផ្សេងៗច្រើនភាសាហ្នឹង វាៗពាក់ព័ន្ធយ៉ាងម៉េចដែរ នៅក្នុងដំណើរការសវនាការយើងនេះ?

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន យើងបានស្តាប់សាក្សីជាច្រើននៅទីនេះ។ ហើយយើងដឹងថា ខ្មែរក្រហមកំណត់

គោលដៅទៅលើបញ្ញាជន ជាពិសេសអ្នកចេះនិយាយភាសាច្រើន អ្នកដែលធ្លាប់ទៅបរទេសអីហ្នឹង ជាមុខសញ្ញា ជាគោលដៅខ្មែរក្រហមហើយ។ អ៊ីចឹងហើយបានជាខ្ញុំសួរគាត់ហ្នឹង ខ្ញុំចង់ដឹង ថាតើលោកឡាច នី ហ្នឹងគាត់អាចមានលក្ខណៈយ៉ាងម៉េច ដែលថាអាច គាត់អាចមានការភ័យខ្លាច ឬក៏គាត់ត្រូវបានគេសង្ស័យថាខ្លួនជាបញ្ញាជន ឬក៏យ៉ាងម៉េច។ នេះវាពាក់ព័ន្ធទៅនឹងវិសាលភាពនៃការជំនុំជម្រះយើង ហើយវាពាក់ព័ន្ធទៅនឹងឯកសារមួយដែលដើមបណ្តឹងរដ្ឋប្បវេណីនេះ គាត់បាននិយាយពាក់ព័ន្ធទៅនឹងបងរបស់គាត់នោះ គឺឯកសារលេខ E3/5640។ ហើយខ្ញុំជិតចប់ហើយលោកប្រធាន។

[១៥:២៥:៣៦]

**ប្រធានអង្គជំនុំ៖**

បាទ អញ្ជើញបញ្ចប់ចុះ!

**សួរដោយកញ្ញា អង់តា ហ្គីសសេះ**

**ស៖** លោកដើមបណ្តឹងរដ្ឋប្បវេណី លោកឆ្លើយថា ក្រោយពីបងថ្លៃ និងកូនៗបាត់ខ្លួន បងលោកហ្នឹងវិកលចរិត គឺដូចឆ្កួត។ ហើយបន្ទាប់មក គេក៏ស្នើឲ្យគាត់ការប្រពន្ធថ្មី។ លោកចាំទេ អ្នកណាជាអ្នកសម្រេចឲ្យបងប្រុសរបស់លោកនុំងការប្រពន្ធថ្មីនោះ គាត់មានឈ្មោះអី? ហើយមានតួនាទីអីដែរ នៅក្នុងភូមិឃុំនោះ?

**លោក ឡាច គ្រី៖**

**ឆ៖** បាទ លោកមេធាវី ដែលសម្រេចឲ្យការ ឲ្យឈ្មោះ ឡាច នី ហ្នឹងការប្រពន្ធថ្មីហ្នឹង គឺមេឃុំមេឃុំស្វាយអន្ទរហ្នឹង រួមជាមួយស្រុក ខាងស្រុកមកដែរ មករួមជាមួយឃុំហ្នឹង ការនៅវត្តស្វាយអន្ទរហ្នឹងចំនួនបីគូ ថ្ងៃនុំងបាទ។

**ស៖** លោកនិយាយថាឃុំ មេឃុំ អ្នកណាជាមេឃុំហ្នឹង ឈ្មោះអីដែរ?

**ឆ៖** បាទ លោកមេធាវី មេឃុំហ្នឹងឈ្មោះ ផែម។ មេឃុំស្វាយអន្ទរ ឈ្មោះ ផែម ហើយនៅស្រុកពីរនាក់ទៀត ខ្ញុំបាទអត់ស្គាល់ទេ ពីព្រោះតែអ្នកក្រៅ អត់ស្គាល់។

**ស៖** តើ ផែម នេះគាត់មានឥរិយាបថយ៉ាងម៉េចចំពោះបងប្រុសរបស់លោក ក្រោយពីឃើញបងលោកក្លាយជាវិកលចរិតហើយនោះ ក្រោយពីបាត់ប្រពន្ធទៅ? តើមេឃុំហ្នឹង គាត់ធ្វើយ៉ាងម៉េចដែរចំពោះបងប្រុសលោកនោះ?

[១៥:២៨:៣២]

**ឆ៖** បាទ លោកមេធាវី ពេលដែលបងស្រីរបស់ខ្ញុំ គេយកទៅបាត់ហ្នឹង បងស្រី -- បងថ្លៃរបស់ខ្ញុំបាទគេយកទៅបាត់នុ៎ង នី ហ្នឹងវាឡើងវិកលចរិត។ ហើយចំពោះមេឃុំវិញ គឺគាត់មានការអាណិតអាសូរដែរ អាណិតអាសូរឈ្មោះ ឡាច នី ដែលឆ្កួត គាត់ឆ្កួតនោះអស់រយៈពេល ដែលឆ្កួតមិនដឹងខ្លួន៥ខែ ហើយដែលគ្រាន់ថាដឹងខ្លួនល្មមតិចៗទេ ដឹងខ្លួនម្តងៗហ្នឹង គឺថាការស្បើយៗទៅ រវាង៥ខែទៀត គិតទៅមួយឆ្នាំបាន ឡាច នី ហ្នឹងដឹងខ្លួន ដូចយើងធម្មតាវិញ។

**ស៖** លោកមេឃុំហ្នឹង គាត់រស់នៅជិត ឬក៏ឆ្ងាយពីផ្ទះបងប្រុសលោក?

**ឆ៖** បាទ មេឃុំនៅឆ្ងាយ នៅប្រហែលជាប់១០គីឡូពី ស្រុកកំណើតរបស់គាត់នៅប្រហែល១០គីឡូពីភូមិរបស់ខ្ញុំបាទហ្នឹង ឆ្ងាយពីភូមិខ្ញុំបាទប្រហែល១០គីឡូ។

**ស៖** ខ្ញុំចង់បានការបញ្ជាក់ជាចុងក្រោយពីលោក មុនផ្តល់វេទិកានេះជូនទៅលោកមេធាវី គង់ សំអុន។ នៅក្នុងឯកសាររបស់លោកគឺ E3/5630 ដែលផ្តល់ជូនមកខាងយើងខ្ញុំដោយមេធាវីរបស់លោក នៅ ERN ជាភាសាបារាំង 00891819 សូមទោសគឺ 1091, ជាភាសាខ្មែរគឺ 00895421, ជាភាសាអង់គ្លេសគឺ 00678290។ លោកបានឆ្លើយថា៖ "អង្គការចង់ឲ្យ ឡាច នី មានសុខភាពផ្លូវចិត្តល្អ ហើយចង់ឲ្យគាត់មានប្រពន្ធថ្មីដើម្បីឲ្យគាត់រស់នៅដោយរីករាយ។ ប្រធានសហករណ៍ ហើយនិងប្រធានឃុំសម្រេចថាឲ្យ ឡាច នី ហ្នឹងរៀបការប្រពន្ធថ្មី។ គេអាណិតគាត់ ប្រធានសហករណ៍ចង់ឲ្យ ឡាច នី ហ្នឹងរស់នៅដោយរីករាយ។" សូមបញ្ចប់ការដកស្រង់។ ក្នុងនេះលោកសំដៅទៅលើ ឆែម ហ្នឹង ឬក៏យ៉ាងណា នៅពេលដែលលោកនិយាយអំពីថាប្រធានសហករណ៍គេចង់ឲ្យ ឡាច នី បងប្រុសលោកហ្នឹងរស់នៅដោយរីករាយហ្នឹង លោកសំដៅលើ ឆែម ហ្នឹងមែនទេ?

**ឆ៖** បាទ គេសំដៅទៅលើរដ្ឋអំណាចភូមិ មិនមែន ឆែម ទេ គឺរដ្ឋអំណាចភូមិផ្ទាល់ដែលក្លាប់គាត់រាល់ថ្ងៃនេះ ក្លាប់គាត់ប្រចាំថ្ងៃនេះ។

**ស៖** លោកអាចជម្រាបឈ្មោះបានទេ អាជ្ញាធរហ្នឹងឈ្មោះអីដែរ?

**ឆ៖** បាទ អ្នករដ្ឋអំណាចភូមិកាលនុ៎ង គាត់ឈ្មោះ សេងៗ។

[១៥:៣២:០១]

**ស៖** សេង នេះគាត់រស់នៅផ្ទះជិតផ្ទះបងប្រុសលោក មែនទេ?

**ឆ៖** សេង នៅឆ្ងាយភូមិដទៃទេ ប៉ុន្តែគេឲ្យភូមិដទៃមកកាន់ធ្វើជារដ្ឋអំណាចនៅភូមិពោធិ៍ចិន្តាំហ្នឹង។ មិត្តសេង ហ្នឹងគឺនៅភូមិពោធិ៍ជ្រៃ ទៅពីផ្ទះខ្ញុំបាទប្រហែលជា២គីឡូ ពីកន្លែងផ្ទះបងប្រុសខ្ញុំហ្នឹង

ប្រហែល២គីឡូ ហើយគេឲ្យមកកាន់ជារដ្ឋអំណាចនៅភូមិពោធិ៍ចិន្តាំហ្នឹង។

**ស៖** អ៊ីចឹងលោកនិយាយអំពីអ្នកណា នៅពេលដែលលោកឆ្លើយថាប្រធានសហករណ៍ចង់ឃើញ ឡាច នី ហ្នឹងសប្បាយចិត្តឡើងវិញហ្នឹង? ព្រោះថានៅ រស់នៅក្បែរគ្នា ហើយអ៊ីចឹងលោកនិយាយពីអ្នកណានៅពេលហ្នឹង ប្រធានសហករណ៍ហ្នឹង?

**ឆ៖** បាទខ្ញុំនិយាយអំពីរដ្ឋ ប្រធានភូមិៗ ឈ្មោះ សេង ហ្នឹងដែលគាត់ថា "អ្នំមានតែរៀបការប្រពន្ធឲ្យទេ បានគាត់សប្បាយចិត្ត គាត់មិនស្ងួរ គាត់ឆាប់ភ្លេចប្រពន្ធកូនរបស់គាត់"។ ហ្នឹងឈ្មោះ សេង ទេ។ បាទ សេង ជារដ្ឋអំណាចភូមិហ្នឹង។

**ស៖** ក៏ប៉ុន្តែលោក លោកថា ឆែម រស់នៅ១០គីឡូម៉ែត្រពីផ្ទះបងប្រុសលោក ហើយ សេង នេះក៏នៅឆ្ងាយដែរ ហើយចុះក្នុងនេះម៉េចក៏ដាក់ថា គេហ្នឹងរស់នៅជិតគ្នាក្នុងឯកសារហ្នឹង?

**ឆ៖** បាទ លោកមេធាវី សេង ដែលគេដាក់ថារស់នៅជិតគ្នាហ្នឹងដោយសារ សេង ហ្នឹងមកពីភូមិរបស់គាត់នោះ មកនៅក្នុងភូមិពោធិ៍ចិន្តាំហ្នឹង មកនៅជាៗប្រធានភូមិ ជារដ្ឋអំណាចភូមិ ចេញពីភូមិមកហ្នឹង មកនៅភូមិពោធិ៍ចិន្តាំហ្នឹង។ បានថា គេដាក់ថាជិតគាត់ ពីព្រោះគាត់នៅក្បែរគាត់មែន នៅក្បែរនៅប្រចាំការនៅភូមិពោធិ៍ចិន្តាំហ្នឹងមែន។

[១៥:៣៤:០៧]

**កញ្ញា អង់តា ហ្គិសសេ៖**

លោកប្រធាន ខ្ញុំអស់សំណួរហើយ។ សូមអនុញ្ញាតប្រគល់វេទិកានេះ ជូនលោកមេធាវី គង់ សំអុន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញលោកមេធាវី គង់ សំអុន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក គង់ សំអុន៖**

**ស៖** បាទ សូមជម្រាបសួរលោកដើមបណ្ដឹងរដ្ឋប្បវេណី។ ខ្ញុំមានសំណួរខ្លីទេដើម្បីសួរលោក។ ទី១ គឺខ្ញុំចង់សួរលោកទាក់ទងទៅនឹងឈ្មោះ ជុយ។ ឈ្មោះ ជុយ នេះលោកបានជម្រាបជូនអង្គជំនុំជម្រះខាងដើមថា បងប្អូនជីដូនមួយស្រីរបស់លោកបានរៀបការជាមួយ។ ហើយពីម្សិលមិញហ្នឹងលោកបាន

បញ្ជាក់ផងដែរថា គាត់ជាអ្នករកស៊ី។ ខ្ញុំចង់សួរលោកថា តើគាត់រកស៊ីអីដែរនៅពេលហ្នឹង នៅពេលដែលគាត់ថា លោកដឹងថាគាត់ជាអ្នករកស៊ីហ្នឹង?

**លោក ឡាច គ្រី៖**

**ឆ៖** បាទ ខ្ញុំសូមជម្រាបលោកមេធាវី។ ជុយ បានខ្ញុំដឹងថាអ្នករកស៊ី ប្រពន្ធគាត់ហ្នឹងនិយាយពីប្រពន្ធ ទាំងប្រពន្ធទាំងប្ដី ប្ដីហ្នឹងគាត់លក់ ជួនកាលត្រី ទទួលត្រីគេយកមកលក់ទៅ។ ហើយប្រពន្ធជួនកាលគាត់ធ្វើនំ ធ្វើនែកអីលក់ទៅ។ ហ្នឹងបានខ្ញុំថាអ្នករកស៊ី មិនមែនជាអ្នកជំនួញជួញដូរអីធំដុំ អត់មានសោះ បើខ្ញុំបាទដឹង។

[១៥:៣៥:៣៣]

**ស៖** បាទ សូមអរគុណ។ គាត់មានរកស៊ីរត់ពន្ធឆ្លងដែនទេ ពីប្រទេសវៀតណាមមកប្រទេសខ្មែរអីចឹង?

**ឆ៖** បាទ លោកមេធាវី រឿងរកស៊ីលក់ -- រកស៊ីរត់ៗឆ្លងព្រំ ខ្ញុំបាទអត់ដឹងទេ។ មិនបានដឹងគាត់យ៉ាងម៉េចៗ អត់ដឹងទេ។ ដឹងថាដែលខ្ញុំធ្លាប់ឃើញគាត់ អាហ្នឹងធ្លាប់ឃើញផ្ទាល់។

**ស៖** បាទ សូមអរគុណ។ លោកចាំឆ្នាំណា ពីឆ្នាំណាដល់ឆ្នាំណាដែរទេ ដែលលោកដឹងថាគាត់រកស៊ីហ្នឹង?

**ឆ៖** គាត់រកស៊ីពីឆ្នាំ៧៤, ៧៥មក ដែលៗខ្ញុំបាទបានដឹងឃើញ ពីព្រោះខ្ញុំនៅផ្ទះក្បែរគាត់ដែរ។ រកស៊ីហ្នឹងគាត់ជួនកាលជួញត្រីទៅ គាត់យកត្រីមកលក់ទៅ កន្លែងផ្សារហ្នឹងទៅ។ ជួនកាលទៅប្រពន្ធគាត់លក់នំអីហ្នឹងចិញ្ចឹមជីវិតទេ តែប៉ុណ្ណឹងទេ ហើយទៅក្រៅពីហ្នឹង ខ្ញុំបាទអត់ដឹងសោះ។ ជំនួញជួញដូរក្រៅប្រទេស ក្នុងប្រទេសអីខ្ញុំបាទអត់ដឹង។

**ស៖** បាទ សូមអរគុណ។ ពីខាងដើមខ្ញុំចាំបានថា លោកស្រីមេធាវី អង់តា ហ្គីសសេ បានបង្ហាញឯកសារពីសាក្សីមួយចំនួនដែលបានបញ្ជាក់ពីរឿងវត្តមានរបស់ឈ្មោះ ជុយ នេះនៅក្នុងភូមិរបស់លោក។ ខ្ញុំចង់សួរបញ្ជាក់លោកថា ដែលលោកឆ្លើយថាលោកស្គាល់ឈ្មោះ ជុយ នេះនៅក្នុងភូមិរបស់លោកមានវត្តមានក្នុងភូមិរបស់លោកក្នុងឆ្នាំ៧៤។ អ៊ីចឹងខ្ញុំចង់សួរថា តើលោកមានអ្វី កាលៈទេសៈអ្វីដែលជាមូលដ្ឋានអាចឲ្យលោកចាំថាជាឆ្នាំ៧៤នោះ ឬក៏ឆ្នាំ១៩៧៤មកនោះ?

[១៥:៣៧:២២]

**ឆ៖** បាទ ជាមូលដ្ឋានរបស់ខ្ញុំដែលដឹង ពីឈ្មោះ ជុយ ហ្នឹងឆ្នាំ៧៤ហ្នឹង ឃើញឆ្នាំ៧៤ហ្នឹងគឺ

គាត់មក ជាមូលដ្ឋានរបស់ខ្ញុំដែលស្គាល់ ព្រោះជាកំណើតកូនរបស់ខ្ញុំមួយនោះ។ ពេលណាកើតបាន ប្រហែលជាមួយអាទិត្យក្រោយមកហ្នឹងគឺ ជុយ ហ្នឹងបានប្រពន្ធ និងប្ដីហ្នឹងនាំមកលេងផ្ទះខ្ញុំហ្នឹង មក សួរសុខទុក្ខអាកូនខ្ញុំកើត។ បានខ្ញុំដឹងថា គាត់មកពីណា? ថាជាប្ដីរបស់ខ្ញុំ នៅក្នុងឆ្នាំ១៩៧៤ ជាភ័ស្ដុតាង ជាក់ស្ដែងនៅលើកូនរបស់ខ្ញុំដែលកើតនោះ។ បានខ្ញុំដឹងសម្គាល់ថាគាត់នេះជាឆ្នាំ៧៤ដែលគាត់មកហ្នឹង។

**ស៖** បាទ សូមអរគុណ។ លោកចាំថាកូនលោកកើតបានអាយុប៉ុន្មានហើយ ដែលគាត់មក ហ្នឹង?

**ឆ៖** បាទ គាត់មកហ្នឹង កូនហ្នឹងទើបកើតបានប្រហែលជា៦ខែកូនហ្នឹង។ គាត់មកលេងផ្ទះខ្ញុំ ហើយ គាត់មកសួរសុខទុក្ខកូនន៎ុង ប្រាំ ប្រហែលប្រាំប្រាំមួយខែប៉ុណ្ណឹង។

**ស៖** បាទ សូមអរគុណ។ លោកៗអាចផ្ដល់ឈ្មោះកូនរបស់លោកបានទេ ថាឈ្មោះអី?

**ឆ៖** បាទ កូនន៎ុងឈ្មោះន៎ែ! ភា ឥឡូវស្លាប់បាត់ហើយ។

**ស៖** បាទ សូមអរគុណ។ លោកមានលិខិតអ្វីនៅសល់ដើម្បីបញ្ជាក់ពីកំណើតកូនហ្នឹងបានទេ?

**ឆ៖** បាទ ខ្ញុំអត់មានទេបង កាលជំនាន់ន៎ុងមានលិខិតឯណាអត់មានទេ ៧០ហ្នឹងគ្មានទេ ស្អីក៏ គ្មានដែរ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំមានសំណួរមួយទៀតទាក់ទងទៅនឹងបងថ្លៃស្រីរបស់លោកជា អតីតភរិយាទី១ របស់លោក ឡាច នី ជាបងប្រុសរបស់លោក។ លោកអាចបញ្ជាក់បានទេថា លោក ស្គាល់បងថ្លៃរបស់លោកដែលជាកូនកាត់វៀតណាមហ្នឹងច្បាស់លាស់ប៉ុនណាដែរ?

[១៥:៣៩:៣៧]

**ឆ៖** បាទ លោក ពីដែលខ្ញុំបាទបានស្គាល់បងថ្លៃរបស់ឯងថាជាវៀតណាមហ្នឹង ពេលដែលគាត់ មកនៅស្រុកឆ្នាំ១៩៦៨ហ្នឹង គាត់ទៅនៅស្រុក។ នៅស្រុក ទី១គាត់និយាយលេងជាមួយបងៗរបស់ខ្ញុំបាទ ហ្នឹងដែលខ្ញុំស្គាល់ដំបូងបំផុតណាស់ គឺបាននិយាយលេងជាមួយបងខ្ញុំ គាត់ចេះវៀតណាមដែរ ចេះ និយាយលេងជាមួយគ្នាហ្នឹងទៅ។ ហើយខ្ញុំក៏សួរគាត់ សួរបងខ្ញុំបាទហ្នឹង សួរថា៖ “អ្ហឺគាត់ហ្នឹង បងឯង យកប្រពន្ធម៉េច? គាត់ថា៖ អ៊ឺ អូនអើយ! បងយកប្រពន្ធវៀតណាម” គាត់និយាយប្រាប់អ៊ីចឹង ហើយ គាត់និយាយលេងវៀតណាមអី ជាមួយប្រពន្ធគាត់ន៎ុងធម្មតាទៅ។ ហើយក្រោយមកទៀត គឺគាត់ហ្នឹង លក់បន្លែ លក់អីទៅ ឃើញបងប្អូនវៀតណាមលក់ត្រី លក់អីទៅ គាត់និយាយ អាចនិយាយ និយាយ ឆ្លើយឆ្លងជាមួយវៀតណាមហ្នឹង បងប្អូនវៀតណាមហ្នឹង។ បាទ ខ្ញុំ--

**សៈ** បាទៗ។ ខ្ញុំចង់សួរបញ្ជាក់បន្ថែម ទាក់ទងនឹងរឿងនិយាយភាសាវៀតណាមនេះ។ បងថ្លៃរបស់លោកហ្នឹង បាននិយាយជាមួយបងប្រុសរបស់លោក ហើយលោកបានស្ដាប់ដោយផ្ទាល់ ឬមួយក៏លោកគ្រាន់តែឮគេនិយាយទេ?

**ឆៈ** បាទ លោកមេធាវី ពីព្រោះផ្ទះ ឡាច នី និងប្រពន្ធ ឡាច នី ហ្នឹងនៅជាប់ផ្ទះខ្ញុំ សំយាបជាប់គ្នា។ ហើយដល់នេះចុះលេង អីខែ ល្ងាចៗទៅចុះលេងដីទៅ គាត់និយាយលេងគ្នាគាត់ហ្នឹងទៅ។ និយាយសើចៗ ប៉ុន្តែខ្ញុំអត់ចេះ មិនដឹងនិយាយរឿងស្អី ខ្ញុំអត់ដឹងដែរ។ ប៉ុន្តែគាត់ហ្នឹងគឺជាប់ផ្ទះខ្ញុំ នៅជាប់គ្នា អត់មានឃ្លាតគ្នាទេ ឃ្លាតគ្នាប្រហែលជា៣ម៉ែត្រតែប៉ុណ្ណឹង ផ្ទះហ្នឹង ផ្ទះខ្ញុំហើយនិងផ្ទះគាត់ហ្នឹងចម្ងាយពីគ្នា។

[១៥:៤១:១៧]

**សៈ** បាទ លោកអាចបញ្ជាក់ពីអំឡុងពេលដែលលោករស់នៅក្នុងផ្ទះជាប់គ្នាដែលលោកថាចម្ងាយ៣ម៉ែត្រហ្នឹង ចាប់ពីឆ្នាំណាដល់ឆ្នាំណា?

**ឆៈ** បាទ ចាប់ទុំងតាំងពីៗសង្គមមក ពីជំនាន់ប្រហែលជា៦៨, ៦៨មក គឺខ្ញុំបានទៅធ្វើផ្ទះនៅក្បែរមន្ទីរស្រុកនុ៎ង។ ហើយដល់ក្រោយមក គាត់មកពីភ្នំពេញអីចឹងមក គាត់ធ្វើផ្ទះនៅជាប់ខ្ញុំទៀត ទាំងឪពុកម្ដាយខ្ញុំ បងប្អូនខ្ញុំទាំងអស់ជុំគ្នាទាំងអស់ មួយក្រុមហ្នឹង។

**សៈ** បាទ សូមអរគុណ។ អីចឹងត្រឹមត្រូវទេ ដែលថា លោកអាចស្ដាប់ឮការជជែក ការនិយាយការទំនាក់ទំនងរបស់បងថ្លៃរបស់លោក ជាមួយបងប្រុសរបស់លោក ក៏ដូចជាជាមួយអ្នកជិតខាង ឬក៏អ្នកណាដែលមកទាក់ទងបងថ្លៃរបស់លោកជាប្រចាំនោះ លោកអាចដឹង។ តើអីចឹងត្រឹមត្រូវទេ?

**ឆៈ** បាទៗ។

**សៈ** បាទ សូមអរគុណ។ នៅក្នុងសវនាការពីម្សិលមិញ ម៉ោងប្រហែលជាបី សុំទោស ម៉ោង១៣:៥០នាទី លោកក៏បានឆ្លើយផងដែរថា ខ្ញុំសូមដកស្រង់៖ លោកធ្លាប់ឮបងថ្លៃរបស់លោកឈ្មោះសាន ហ្នឹងនិយាយភាសាវៀតណាមទេ? (គេសួរ) ហើយឆ្លើយ គឺថាលោកឆ្លើយថា៖ បាទ ខ្ញុំបានធ្លាប់ឮ។" ហើយក្រោយហ្នឹងបន្តិច លោកក៏បានឆ្លើយផងដែរថា សូមដកស្រង់៖ "គាត់ច្រើននិយាយវៀតណាម បានប្រជាជនទាំងអស់ហ្នឹង គេអាចដឹងថា គាត់សន្និដ្ឋានថា គាត់វៀតណាម ពីព្រោះចេះនិយាយវៀតណាម ហើយនិយាយប៉ែឡាំៗរបៀបវៀតណាម។" ហើយក្រោយមកទៀត ក្នុងម៉ោង១៥:៥០ លោកបានបញ្ជាក់ផងដែរថា សូមដកស្រង់៖ "ដល់និយាយភាសាខ្មែរ រាងៗប៉ែឡាំៗបន្តិច គាត់ហ្នឹង។"

អ៊ីចឹងខ្ញុំឃើញនៅក្នុងសក្ខីកម្មរបស់លោកនេះ គឺលោកបាននិយាយជាច្រើនដង អំពីបងថ្លៃស្រីរបស់លោក ថាចេះនិយាយភាសាវៀតណាម ហើយនិយាយខ្មែរប៉ែឡាំៗ។ តើលោកនៅ លោកប្រកាន់អ៊ីចឹងថា ជាសក្ខីកម្មរបស់លោកទេ?

[១៥:៤៣:៥៤]

**ឆ៖** បាទ ដែលខ្ញុំបាទជម្រាបពីម្សិលមិញ គឺខ្ញុំជម្រាបដូចអ៊ីចឹងដែរ ថាគាត់និយាយភាសាវៀតណាម ហើយនិយាយខ្មែរភាសា វាច្រើនប៉ែឡាំ។ ហើយដែលគាត់និយាយច្រើនវៀតណាមហ្នឹង គឺវៀតណាមៗគ្នាគាត់នុ៎ង ដើម្បីមកទិញបន្លែរបស់គាត់ហ្នឹង ច្រើននិយាយភាសាវៀតណាម។ ប៉ុន្តែបើនិយាយជាមួយបងប្អូនយើង និយាយភាសាខ្មែរច្រើនប៉ែឡាំអ៊ីចឹងមែន បាទ អ៊ីចឹង។

**ស៖** បាទ ដើម្បីឲ្យច្បាស់ លោកអាចបញ្ជាក់ពីឈ្មោះបងថ្លៃស្រីរបស់លោកទី១ ដែលជាប្រពន្ធរបស់ ឡាច នី ហ្នឹងទេ បានទេ?

**ឆ៖** បាទ ឈ្មោះគាត់ ឈ្មោះ សំ សាន។

**លោក គង់ សំអុន៖**

បាទ សូមអរគុណ។ លោកប្រធាន សូមអនុញ្ញាតដកស្រង់ចាក់នូវឯកសារមួយ ដែលមានលេខសម្គាល់ជា D166/12R ដែលជាផ្នែកមួយនៃឯកសារស្តាប់សំឡេង។

បាទ សុំអធ្យាស្រ័យលោកប្រធាន ដោយសារអត់មានវីដេអូ សំឡេង ជាខ្សែសំឡេង ខ្សែអាត់សំឡេងចាក់ អ៊ីចឹងខ្ញុំបាទសុំដកស្រង់នូវការរៀបរាប់របស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលមានឯកសារដូចបានជម្រាបជូនអំមិញ ត្រង់នាទី០៨:០៥៨ ដល់០៩:០១០ អ៎សូមទោស១០។ សូមដកស្រង់៖ “ប្រពន្ធហ្នឹងគឺកូនកាត់វៀតណាម? ឡាច គ្រី គាត់ឆ្លើយ៖ បាទ កូនកាត់វៀតណាម ប្រពន្ធហ្នឹង ប៉ុន្តែវាចង់ទៅជាខ្មែរហើយ។ គាត់អត់ទាំងចេះយួនផង។ សូរិយាសួរ៖ បាទ ប្រពន្ធកាត់វៀតណាម គាត់អត់ចេះនិយាយខ្មែរទេ? ឡាច គ្រី៖ អត់ចេះនិយាយយួនផងហ្នឹង។ សូរិយា៖ អ៎! អត់ចេះនិយាយយួនទេ? ឡាច គ្រី៖ បាទ អត់ចេះផង។” បាទ ខ្ញុំបានព័ត៌មានថាមានខ្សែអូឌីយោ អ៊ីចឹងខ្ញុំសុំអនុញ្ញាតលោកប្រធាន ដើម្បីចាក់សំឡេងរបស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ដើម្បីឲ្យគាត់ស្តាប់ បាទ។ សូមអរគុណ។

[១៥:៤៦:៤១]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

**លោក គង់ សំអុន៖**

បាទ លោកប្រធានសូមអធ្យាស្រ័យ ដោយសារអូឌីយោនេះជាផ្នែក ខ្សែអូឌីយោរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ហើយយើងមិនបានស្នើសុំឲ្យចាក់ទេ។

**សួរដោយលោក គង់ សំអុន៖**

**ស៖** អ៊ីចឹងខ្ញុំសូមអនុញ្ញាតសួរបន្តទៅលោក ឡាច គ្រី។ លោកចាំបាននូវសក្ខីកម្មដែលលោកបានផ្ដល់ឲ្យខាងការិយាល័យស៊ើបអង្កេតនោះទេ នៅពេលដែលលោកទៅធ្វើ លោកបានទទួលការសម្ភាសនៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០០៨? លោកចាំបានសម្ដីដូចដែលខ្ញុំបានអានជូនអម្បាញ់មិញទេ?

**លោក ឡាច គ្រី៖**

**ឆ៖** បាទ ខ្ញុំបាទអត់ចាំទេ វាភ្លេចៗអស់ បាទភ្លេចហើយមិនដឹងជាថ្ងៃណាវា អត់បានចាំវាយូរពេក។

**ស៖** បាទ សូមអរគុណ។ ចុះលោកមានចាំខ្លឹមសារទាក់ទងទៅនឹងការប្រើភាសារបស់បងថ្លៃលោកទេ ថាដែលលោកឆ្លើយថា បងថ្លៃលោកហ្នឹងអត់ចេះភាសាវៀតណាមទេនៅពេលនោះ។ លោកមានចាំទេ?

**ឆ៖** បាទ ខ្ញុំបាទអត់ចាំទេបង ពីព្រោះដូចជារឿងហ្នឹងអត់ពិតផង។ ខ្ញុំសូមបដិសេធ អត់ មិនមែនថាគាត់មិនមែនចេះភាសាវៀតណាម គឺគាត់ចេះ។ គឺខ្ញុំមិនដែលនិយាយថា មិនចេះទេ គឺតែនិយាយថាចេះអ៊ីចឹងតែម្ដង។ ប៉ុន្តែគ្រាន់ថា ក្នុងការចេះតិចច្រើន ខ្ញុំបាទអត់ដឹងទេកាលនោះ ជំនាន់នោះ ទើបដឹងក្រោយៗមក បានដឹងថាគាត់ជាវៀតណាម។

[១៥:៤៩:០១]

**ស៖** បាទ សូមអរគុណ។ លោកចាំពីៗចំណុចដែលផ្ទុយគ្នារវាងដែលថា លោកប្រាប់មកខាងការិយាល័យស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេតថា បងស្រីថ្លៃរបស់លោកហ្នឹងមិនចេះភាសាវៀតណាមទេ។ ក៏ប៉ុន្តែក្រោយមក ក្នុងពេលសវនាការនេះ លោកឆ្លើយថា បងថ្លៃលោកចេះភាសាវៀតណាម។ ខ្ញុំចង់សួរបញ្ជាក់ថា តើវាជាការភ័ន្តច្រឡំ ឬក៏ការភ្លេចភ្លាំង ឬក៏វាមានបញ្ហាណាមួយដែលធ្វើឲ្យលោកបង្ហាញនូវភាពផ្ទុយគ្នានេះ? លោកអាចបញ្ជាក់បានទេ?

**ឆ៖** បាទ លោកមេធាវី រឿងដែលខ្ញុំថា គាត់នេះមិនចេះវៀតណាម គឺខ្ញុំបាទមិនដែលនិយាយទេ មិនដែលនិយាយថា គាត់មិនចេះវៀតណាម គឺមិនដែលនិយាយ ពីព្រោះគាត់ជនជាតិវៀតណាម ត្រូវតែ

ចេះវៀតណាម។ ហើយដល់ថា ខ្ញុំមិនថាមិនចេះហ្នឹង គឺថាខ្ញុំមិនបានដឹងទេ អារឿង ហ្នឹងអត់បានដឹង។

**លោក គង់ សំអុន៖**

បាទ សូមអរគុណ។ ខ្ញុំគ្រាន់តែចង់បញ្ជាក់លោកថា អ្វីដែលលោកបានអាននេះ គឺជាការដកស្រង់ចេញពីខ្សែអាត់សំឡេងរបស់លោក នៅពេលដែលការិយាល័យសហចៅក្រមស៊ើបអង្កេតទៅសម្ភាសលោក។ ដូច្នេះលោកឆ្លើយមានការផ្លាស់ប្តូរ អានោះខ្ញុំក៏មិនដឹងពីភាពជាក់ស្តែងដែរ ក៏ប៉ុន្តែខ្ញុំគ្រាន់តែសុំឲ្យលោកធ្វើការពិនិត្យសាឡើងវិញ បើសិនជាលោកមានការភ័ន្តច្រឡំ។ អានេះគ្រាន់តែជាសំណួររបស់ខ្ញុំទេ។ អ៊ីចឹងសូមអរគុណលោកប្រធាន ហើយលោកដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំអស់សំណួរហើយ។

[១៥:៥១:០៨]

**ប្រធានអង្គជំនុំ៖**

បាទ ហើយអង្គជំនុំជម្រះសូមអរគុណលោក ឡាច គ្រី។ សវនាការស្តាប់សក្ខីកម្មរបស់លោកហ្នឹងបានចប់ហើយ ហើយដោយថាលោកជាដើមបណ្តឹងរដ្ឋប្បវេណី ជាចុងក្រោយនេះ គឺលោកមានសិទ្ធិក្នុងការថ្លែងរៀបរាប់ប្រាប់ដល់អង្គសវនាការស្តាប់អំពីរឿងហេតុទំនាក់ទំនង និងបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ទៅលើជនជាប់ចោទទាំងពីររូប នួន ជា និង ខៀវ សំផន ដែលបានប៉ះពាល់ចំពោះលោកនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលនាំឲ្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប្តឹងទាមទារសំណងជំងឺចិត្តនិងជាសមូហភាពពីជនជាប់ចោទ និងពីស្ថានភាពព្យសនកម្មដែលមានចំពោះលោកជាអាទិ៍ ការខូចខាតខាងរាងកាយ សម្ភារៈ ផ្លូវចិត្ត និងផលវិបាកដោយផ្ទាល់ពីបទឧក្រិដ្ឋជាព្យសនកម្មផ្ទាល់ខ្លួន ដែលបានកើតមានពិតប្រាកដរហូតដល់ពេលនេះ ប្រសិនបើលោកមានបំណងធ្វើដូចម្តេច លោក ឡាច គ្រី។

**លោក ឡាច គ្រី៖**

បាទ លោកប្រធាន ខ្ញុំបាទសូមគោរព ព្រោះពេលកន្លងមកដែលខ្ញុំបាទរួមរស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យហ្នឹង គឺវេទនាជាទីបំផុតចំពោះរូបខ្ញុំ ម្តាយខ្ញុំ ឪពុកខ្ញុំ បងខ្ញុំ។ ពេលកន្លងមកហ្នឹង គឺគាត់ហ្នឹង អស់រយៈពេល៥ឆ្នាំកន្លងមកហ្នឹងគឺវេទនា វេទនាប្រហែលជាហាហុកសិបភាគរយទេ ចាប់ពីឆ្នាំ៧៥ មកទាល់នឹង៧៩ហ្នឹង គឺវេទនារកអ្វីប្រៀបពុំបានទេ។ ទីបំផុតហ្នឹង ដែលខ្ញុំបាទ គេជម្លៀសទៅនៅខេត្តបាត់ដំបងនោះ។

[១៥:៥២:៥១]

មុនដំបូងធ្វើដំណើរចេញពីខេត្តបាត់ដំបងទៅ -- ធ្វើដំណើរចេញពីខេត្តព្រៃវែងទៅចូលខេត្តបាត់ដំបងហ្នឹង អស់រយៈពេល៣ថ្ងៃ ជិះ ហៅសាឡាង់ៗហ្នឹង ខ្ញុំបាទក៏មិនសូវជាអ្នកស្គាល់ដែរសាឡង់ហ្នឹងដូចទូក។ ជិះសាឡង់ហើយ ឡើងពីសាឡង់ទៅឡើងរទេះភ្លើង។ ឡើងរទេះភ្លើងទៅដល់កាឡោមភ្នុកហ្នឹង ខ្ញុំបាទហ្នឹង គេដាក់ចោលនៅផ្លូវរទេះភ្លើងហ្នឹង។ ហើយចម្ងាយផ្លូវរទេះភ្លើងទៅកន្លែងអាងទុំលែងចម្ងាយប្រហែលជាប្រាំពីរប្រាំបីគីឡូ។ ខ្ញុំក៏មិនដឹងថា ការរស់នៅកន្លែងដីខ្លាញ់ហ្នឹងរបៀបម៉េច អត់ដឹងទេ។ ខ្ញុំបាទគឺថាមានឪពុកម្ដាយចាស់ជរា។ ដូច្នេះខ្ញុំរែក រែកឪពុកខ្ញុំ ម្ដាយខ្ញុំ រែក រែកគាត់ ហើយនិងគ្រួសារទូលជាគ្រឿងសម្លៀកបំពាក់បន្តិចបន្តួច។ ដល់ទៅដល់នុំងភ្លាម មិនទាន់បានមួយម៉ោងផង គេបំបែកគ្រួសារអស់ បំបែកគ្រួសារខ្ញុំបាទអស់។ ប្រពន្ធដោយប្រពន្ធ កូនដោយកូន ឪពុកដោយឪពុក ម្ដាយដោយម្ដាយ។ ដូច្នេះខ្ញុំរងទុក្ខវេទនាជាទីបំផុត ពេលកន្លងមកនុំង។ អស់រយៈពេលមួយខែកន្លងមក គឺខ្ញុំបាទដើរទៅច្រូតតែស្រូវ។ ដល់ច្រូតស្រូវ ហើយបាយ តែបាយហូបហ្នឹងគឺគ្មានអីទេ គឺមានតែបាយ ហើយនិងខ្ទឹមបុកអំបិល ជាប្រចាំថ្ងៃអ៊ីចឹងតែម្ដង។ បាយខ្ទឹម បាយហើយ ហូបបាយនឹងអំបិលបុកខ្ទឹមហ្នឹង ស្លឹកខ្ទឹមហ្នឹង។ បាទ ជារាល់ថ្ងៃរយៈពេលពីរខែ ស្ទើតែដាច់ខ្យល់ស្លាប់។

[១៥:៥៤:២៩]

ពេលកន្លងមកទៀតនោះ គឺមានប្រជុំមួយ ហៅថា មហាសន្និបាតធំរបស់កម្ពុជាប្រជាធិបតេយ្យ គឺពីអ្នកដឹកនាំនៅៗអាងទុំលែងហ្នឹង ក៏ហៅប្រជុំ។ ប្រជុំប្រជាជនចំនួនប្រហែល៦.០០០នាក់ ទៅពីបូព៌ាទៅ ទៅប្រជុំហ្នឹង។ នៅកន្លែងនោះគឺថា ខ្ញុំបាទហ្នឹងគឺអង្គុយក្រោយគេ ចម្ងាយពីមេប្រជុំហ្នឹងប្រហែលជា ចម្ងាយសាមសែសិបម៉ែត្រនោះ គ្នាច្រើនពេក អង្គុយក្រោយ។ ពេលកន្លងនោះហើយ ដែលមានឈ្មោះមួយឈ្មោះថាលោក នេៗ ហ្នឹងទៅពីពោធិ៍ចិន្តុំខ្ញុំបាទហើយ ភូមិកំណើតនៅពោធិ៍ចិន្តុំដែរ។ លោកបានឆ្លើយជម្រាបប្រាប់អង្គប្រជុំថា ឲ្យអង្គប្រជុំហ្នឹង ដើម្បីឲ្យមាន ឲ្យអស់លោកទាំងអស់ហ្នឹងមានមតិ អ្នកណាមានមតិខ្លាំង ឲ្យៗឡើងៗមានមតិ។ មិត្ត នេ ទៅចុច ប្រធានកងនោះ ថាអ្នំមានតែឈ្មោះ ឡាច គ្រី ទេគាត់ជាក្នុងគណៈតំបន់។ ចោទខ្ញុំបាទថាជាគណៈតំបន់ ប៉ុន្តែការពិតហ្នឹង ខ្លួនខ្ញុំនេះអ្នកស្រែសុទ្ធ គ្មានទៅស្គាល់អីឯណារឿងៗគណៈតំបន់ គណៈតំបន់មិនដឹងជាគណៈតំបន់របៀបម៉េចផង ខ្ញុំអត់ស្គាល់សោះ។

ពេលកន្លងមកហើយ ក្រោយមកនោះ ខ្ញុំបាទហ្នឹងក៏រយៈពេលបីថ្ងៃ កន្លងមកគេឲ្យទៅធ្វើការជាធ្វើផ្ទះ ផ្ទះនៅកាប់ដំបូកនោះ ធ្វើផ្ទះៗ ទទឹង៣ម៉ែត្រ បណ្ដោយ៣ម៉ែត្រ។ បាទធ្វើទៅ ដេកនៅនឹងដំបូក

នុ៎ង។ ដល់ក្រោយមកទៀត រយៈប្រហែលជាមួយអាទិត្យក្រោយមក គេនាំខ្ញុំបាទហ្នឹងទៅឲ្យទៅធ្វើត្រី នៅខាងទន្លេសាប គ្នាប្រហែល៥០នាក់។ ទៅដល់កន្លែងមួយនោះ គឺខ្ញុំបាទហ្នឹងដើរៗទៅ ព្រលប់ៗ ប្រហែលជាម៉ោងប្រាំមួយ ព្រលៗហើយ ពួកវាហ្នឹង ពួកខាង ប៉ុល ពតហ្នឹង១០នាក់ ដើរយាមពីក្រោយ ពួកខ្ញុំប្រហែលជា៥០នាក់។ ដល់នោះវាបាញ់រះពីក្រោយ។ បាញ់រះពីក្រោយ ខ្ញុំបាទនេះនៅដៃជាប់ចំណង ទេ នៅៗជាប់ចំណងខ្សែអង្រឹង នៅចងជាប់ចំណង ហើយខ្ញុំបាទក៏រត់។ រត់ទៅគឺបាញ់ងាប់អស់ ច្រើន ខ្ញុំបាទមិនបានដឹងទេ ងាប់ប៉ុន្មានៗអត់បានដឹងទេ។ អ្នកដែលរត់ទៅជាមួយខ្ញុំបាទហ្នឹង គឺគ្នា១២នាក់ រត់ទៅ ជាមួយខ្ញុំបាទហ្នឹង។ ១២នាក់ក៏រួចខ្លួន បានឆ្លងទៅហួលទៅផ្លូវរទេះភ្លើង ហួសកាឡោមភ្លុកហ្នឹងទៅផ្លូវ រទេះភ្លើង ដើម្បីសំដៅមកពោធិ៍សាត់។

[១៥:៥៦:៤៨]

ដល់សំដៅមកពោធិ៍សាត់ អស់រយៈពេល៧ថ្ងៃគឺអត់មានអីហូបសោះ ទទេសុទ្ធតែទឹក។ បាទ ហើយរត់មក៧ថ្ងៃហ្នឹងទៀត គឺខ្ញុំបាទរត់មកហ្នឹងទៅ ពួកវាហ្នឹងក៏បានប្រកាស កាលនុ៎ងមានវ៉ាដ្យូមួយ ពួកវាមានវ៉ាដ្យូ។ ប្រកាសថា "ឈ្មោះ ឡាច គ្រី ហ្នឹងជាមេខ្លោងដឹកនាំបះបោររត់"។ ជាការពិតគឺខ្ញុំបាទ ជានាំពួក១២នាក់ហ្នឹងរត់ទេ មិនមែនអ្នកបះបោរអីទេ។ ការពិតវាបាញ់រះងាប់ ពួកហ្នឹងងាប់ ស្លាប់អស់ ទៅ ខ្ញុំក៏រត់រួចទៅ ១២នាក់ហ្នឹង។ ១២នាក់ហ្នឹងស្រីបួននាក់ ប្រុសប្រាំបីនាក់។ ហើយដល់ខ្ញុំបាទរត់កាត់ ឆ្លងទៅ ឆ្លងសមរភូមិ ចំនួនបីសមរភូមិ។ សមរភូមិទី១នោះ គឺត្រៀមសុទ្ធតែកាំភ្លើងធំ។ បាទ ខ្ញុំបាទរត់ កាត់ឆ្លងសមរភូមិនុ៎ង គឺថាកាំភ្លើងបាញ់ៗងាប់ៗអស់បួននាក់ទៀត ងាប់អស់បួននាក់។ ដូច្នេះវានៅៗ សល់តែប្រាំបីនាក់ទេ។ សល់ប្រាំបីនាក់ហ្នឹង ខ្ញុំបាទឆ្លងកាត់សមរភូមិមួយទៀត។ ទី២ សមរភូមិដែលជា សមរភូមិស្លាប់រស់ ទី២ហ្នឹង គឺរួបខ្ញុំបាទហ្នឹងរត់រុលទៅវិលនឹងដំបូក គេបាញ់មួយប្រាវខ្លាំងទៅ ខ្ញុំរត់ ចូលដំបូក ស្មានតែរត់ចូលផ្លូវខ្មោច ខ្មោចគរ។ ខ្មោចគឺថារាប់មិនអស់ទេបាទ រាប់មិនអស់ ក្នុងជើងដំបូក ហ្នឹង ជាប់ប្រហែល២០, ៣០ខ្មោច ៥០ខ្មោច គរពេញនុ៎ង។ ខ្ញុំបាទបើករុលចូលក្នុងខ្មោច កប់ទៅ ពួក ដែលរត់ចេះតែរត់ទៅ អ្នកណារត់ទៅមុខ។ នៅសល់ប្រាំបីនាក់ រត់ៗ ខ្ញុំបាទរត់ទៅតាមក្រោយទៅ ពួក គេត្រឡប់ទៅវិញ ខ្ញុំរត់តាមក្រោយទៅ។ តាមក្រោយ ឃើញពួកខ្ញុំស្លាប់នោះពីរនាក់ទៀត ស្លាប់នៅ សមរភូមិទី២ ខ្សែក្រវាត់ទី២ហ្នឹង។

[១៥:៥៨:២៦]

ដល់ចូល បាននៅសល់ប្រាំមួយនាក់ ស្រីស្លាប់ម្នាក់ហើយនៅសល់បីនាក់។ ដល់រត់ទៅទៀត

ទៅៗ ទៅចូលខ្សែក្រវាត់ទី៣ ខ្សែក្រវាត់ដែលខ្សែក្រវាត់ព្រំដែនរបស់ពោធិ៍សាត់ នៅៗត្រង់ហ្នឹងន៎ស្វាយដូនកែវ បាទស្វាយដូនកែវត្រង់នុ៎ង។ ខ្ញុំឆ្លងមកកាត់សមរភូមិមួយទៀតៗ បាញ់ងាប់ទៀតបាទ បាញ់ងាប់នារីហ្នឹងមួយទៀត នៅសល់នារីពីរទេ ប្រុសស្លាប់មួយទៀត។ បាទ នៅសល់ប្រាំនាក់ទាំងអស់។

ហើយខ្ញុំសុំជម្រាបដល់ ស្លាប់ហ្នឹងហើយដែលខ្ញុំបានរត់ចេញផុតខ្មោចទៅ គឺខោអាវគ្មានទេគឺរលីងគឺអស់រលីង។ ចំណែកនារីវិញ ពីរនាក់នោះទៀត សូមអភ័យទោស វាហួសស្រាតទៀត។ មានខោឯណាស្លៀក ខោអាវរហែករលីងអស់ អត់មានឯណានេះ មានតែខ្ញុំបាទហ្នឹងហើយអ្នកយកខោ ខោខ្លី ខ្ញុំបាទហ្នឹងសុខចិត្តស្រាតខោខ្លីខ្លួនឯងឲ្យទៅនារីស្លៀក ហើយខ្ញុំស្រាតខោវែងរហែកអស់រលីង សុខចិត្តយកមកស្លៀកចងក្បិនរូបខ្ញុំបាទនេះ។

រត់ទៅមកដល់ពោធិ៍សាត់ មកដល់ពោធិ៍សាត់ ខ្ញុំបាទរត់ចូលទៅខាងបន្ទាយវៀតណាម កាលហ្នឹងវៀតណាមចូលមកហើយ។ ហើយបន្ទាយវៀតណាមហ្នឹង វៀតណាមហ្នឹងក៏ចាប់ខ្ញុំបាទដាក់គុកទៀត។ គ្នាប្រាំនាក់ចាប់ដាក់គុក ថាខ្ញុំហ្នឹងប៉ុល ពត។ ពេលនោះដែលវេទនាបំផុតនៅក្នុងខេត្តពោធិ៍សាត់នៅកន្លែងរថនាហ្នឹង ក្បាលស្ពានពោធិ៍សាត់ហ្នឹង ចាប់ខ្ញុំបាទដាក់គុក។ ដាក់គុកហើយ ពេលនោះសួរខ្ញុំបាទ សួរថា ខាងអាំងទែរប្រែតរបស់វៀតណាមហ្នឹង សួរខ្ញុំថា៖ “បងឯង! ប៉ុល ពត ហីក៏មិនមែនទេ? ខ្ញុំថា៖ ខ្ញុំមិនមែនទេ។ ខ្ញុំជាប្រជាជននៅខាងព្រៃវែង។ ហើយគាត់ក៏ថាទៀត គាត់ថា៖ មិនមែនទេ លោកឯង ប៉ុល ពត”។ សួរខ្ញុំ ហើយសួរខ្ញុំ ទះកំផ្លៀងខ្ញុំមួយដៃ បាទទះកំផ្លៀងខ្ញុំមួយដៃ ទះកំផ្លៀងមួយដៃ ខ្ញុំថា “លោកឯង ម៉េចក៏ទះខ្ញុំចឹ? ថាលោកឯងនេះ ប៉ុល ពត ម៉េចក៏ឆ្លើយថា មិនថាប៉ុល ពត។ បានខ្ញុំបាទនេះក៏វាខឹងពេក រកថាបើនៅឆ្លើយថា មិនមែនក៏ស្លាប់ អាមែនក៏ស្លាប់។ ដូចនេះខ្ញុំបានសម្រេចចិត្តខ្លួនឯងតែម្តង ឆ្លើយថា៖ “ឥឡូវបើលោកឯង ចោទខ្ញុំថា ប៉ុល ពត ខ្ញុំក៏ទទួលស្គាល់ថា ប៉ុល ពត ដែរ។ ប៉ុន្តែខ្ញុំសួរវិញ សួរអស់លោកវិញ តើលោកឯងកាលជំនាន់ ប៉ុល ពត លោកឯងរត់ទៅនៅប្រទេសណា?” ខ្ញុំបាទសួរ វាអស់ក្តីសង្ឃឹមរបស់ខ្ញុំហើយ ខ្ញុំសួរអ៊ីចឹងតែម្តង។ លោកឯងទៅនៅប្រទេសណា? ហើយគាត់ហ្នឹងបានតែ៖ “អញក៏នៅប្រទេសហ្នឹងដែរ នៅពោធិ៍សាត់ហ្នឹងដែរ”។ បានខ្ញុំបាទហ្នឹងថា៖ “ថាបើលោកឯងនៅពោធិ៍សាត់ ក៏លោកឯងជំនាន់នោះ ក៏លោកឯង ប៉ុល ពត ក្តោបក្តាប់ដែរ ដូច្នេះលោកឯងក៏ប៉ុល ពតដែរ។ បើខ្ញុំ ប៉ុល ពត លោកឯងក៏ប៉ុល ពតដែរ។ ខ្ញុំគ្រាន់តែថាប៉ុណ្ណឹង វ៉ៃក្បាលខ្ញុំមួយកាំភ្លើងខ្លីនេះ បីកាំភ្លើង។ ឈាមហូរបាញ់ ឈាមហូរជោគខោអាវអស់។ ហើយដាក់ខ្នោះខ្ញុំរហូត។ បាទ ដាក់ខ្នោះខ្ញុំរហូតអត់មានដែលលែងទេ។ មុនគ្រាន់តែដាក់រាងធូរ ដល់ខ្ញុំឆ្លើយអ៊ីចឹង គេធ្វើបាបខ្ញុំ ហើយយកទៅដាក់គុក

ធ្ងន់ជាទីបំផុត។

[១៦:០១:២៥]

ដល់ចុងក្រោយបំផុត គឺកាលនុំង ខ្ញុំបាទជាប់គុកអស់រយៈ១ខែ២០ថ្ងៃ ជាប់គុកនៅក្នុងកន្លែងរចនាហ្នឹង អគារហ្នឹង។ ដល់ចុងក្រោយមក គឺបានគុណ គឺឯកឧត្តម ព្រហ្ម ខិន។ ឯកឧត្តម ព្រហ្ម ខិន គាត់ពីដើម ដឹងគាត់នៅខាងអីទេ ប៉ុន្តែនេះគាត់មកហ្នឹង។ មកហ្នឹងគាត់ ចេះខ្ញុំបាទស្គាល់ ក៏គាត់ ពីព្រោះគាត់នៅភូមិក្បែរខ្ញុំបាទដែរ។ ខ្ញុំសួរ គាត់ឃើញដាក់ ឃើញខ្ញុំ ដល់ហើយខ្ញុំលើកដៃ លើកដៃ គាត់ចេះតែឆ្ងល់ ខ្ញុំចេះតែមើល។ សួរខ្ញុំថា៖ “បងឯងនៅឯណា? ខ្ញុំបាទ៖ នៅស្វាយអន្ទរ ខ្ញុំក៏ស្គាល់លោកដែរ ព្រោះលោកឯងនៅក្បែរផ្ទះខ្ញុំដែរ។ ថា៖ អ្ហឺ! ចុះអាពួកព្រៃវែងទេ? បាទ ពួកព្រៃវែង។” ដូច្នេះគាត់ឲ្យដោះខ្ញុំម្នាក់ហ្នឹង ដោះម្នាក់ហ្នឹងដើម្បីលែង១ខ្ញុំ ដើម្បីគាត់ចង់សួរ សួរខ្ញុំប្រាប់សារបណ្ណអស់ទៅ គាត់ក៏បញ្ជាឲ្យវៀតណាមដោះលែងខ្ញុំ ប៉ុន្តែវៀតណាមអត់ដោះ។ ដល់ពេលចុងក្រោយមក គាត់ត្រឡប់ទៅវិញបាត់ទៅ បានវៀតណាមដាក់គុកខ្ញុំ ជាប់ខ្នោះដដែល។

ហើយដល់ពេលនោះមាន កាលនុំង បែក០៧មករាហើយ។ ០៧ មករាហើយ ប្រជាជនដែលទៅដីខ្លាញ់ទាំងអម្បាលម៉ានត្រឡប់មកវិញអស់។ *(ឮមិនច្បាស់)* ព្រោងព្រាត១ ខ្ញុំបាទគឺនៅជាប់គុកហ្នឹង អត់ដឹងទេ អត់ដឹងថា បងប្អូនឯងនៅត្រង់ណាអីណា។ ដល់ពេលក្រោយមកឃើញ ឡាច នី ហ្នឹង។ ឡាច នី គឺបងប្អូនខ្ញុំ អ្នកដទៃគេស្គាល់ ក៏បក់ដៃហៅខ្ញុំ គាត់រត់មកឱបខ្ញុំ។ រត់មកឱបខ្ញុំ ហើយបានប្រជាជនប្រហែលជាប់១០០នាក់ ក៏គាំទ្រខ្ញុំ ឲ្យដោះលែងគាត់ទៅ គាត់ជាអ្នកល្អណាស់។ ហើយខ្ញុំបានរត់ទៅរកប្រពន្ធកូននុំងថា ប្រពន្ធកូនម៉ែឪស្លាប់អស់ហើយ។ បាទស្លាប់អស់ហើយ គេសម្លាប់ចោលអស់ហើយ ដោយសារបងឯង ពួងឯងរត់។ បើមិនរត់ ក៏ខ្ញុំស្លាប់។ រត់មកក៏ស្លាប់ ជៀសក្រែងរកស្លាប់ ឬមុនស្លាប់ រត់មកនេះ។ ដល់នេះខ្ញុំបានរត់ បានឮជ័យជម្នះខាង ថាមិនស្លាប់មែន។ ប៉ុន្តែម្តាយខ្ញុំ--

**ប្រធានអង្គជំនុំ៖**

បាន១ ប៉ុណ្ណឹងសិន ហើយមានខូចខាតអីខ្លះទៅ ជាសាច់ញាតិសន្តានអី ឬក៏ផ្ទាល់ខ្លួនអីមានត្រូវរបួស មានអីឈឺចាប់កម្រិតណាទៅ លោក ឡាច គ្រី? ព្រោះពេលវេលាដូចជាអស់ហើយណ៎ា។

**លោក ឡាច គ្រី៖**

បាទ ខ្ញុំសូមលោកប្រធានជ្រាប ខ្ញុំបាទរបួសចង្កេះ ត្រូវចង្កេះហ្នឹងគឺថាត្រូវគ្រាប់ ត្រូវជាទីបំផុតចង្កេះហ្នឹង។ ហើយខូចខាតរបស់របរខ្ញុំហ្នឹង មានអី ខោអាវសម្លៀកបំពាក់ទាំងអស់នោះ គឺចោលទាំង

អស់ គ្មានទេ។ ហើយផ្ទះសម្បែងនេះមកវិញ គេរើកម្ទេចទៀត រលីងទៀត។ បាទ ខ្ញុំសូមជម្រាបដែលសំខាន់ដែលខ្ញុំជាងគេ គឺឪពុកម្ដាយរបស់ខ្ញុំ ប្រពន្ធរបស់ខ្ញុំ កូនរបស់ខ្ញុំ ប្អូនរបស់ខ្ញុំ និងបងរបស់ខ្ញុំហ្នឹង ហើយនិងបងប្អូនរួមជាតិដែលនៅក្នុងភូមិរបស់ខ្ញុំផ្ទាល់ហ្នឹង គឺសោកស្ដាយជាទីបំផុត។ ហ្នឹងខ្ញុំសូមមានមតិប៉ុណ្ណឹង លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ ហើយយ៉ាងម៉េចទៅ?

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ដោយសារតែដល់ម៉ោងហើយ ខ្ញុំឃើញថា លោកប្រធានមិនទាន់បានផ្ដល់ឱកាសឲ្យដើមបណ្ដឹងរដ្ឋប្បវេណី សួរសំណួរទៅជនជាប់ចោទនៅឡើយទេ។ យើងបានផ្ញើតាមអ៊ីម៉ែលរួចមកហើយ។ ដូច្នេះសូមលោកប្រធានមេត្តាអនុញ្ញាតផ្ដល់ឱកាសឲ្យដើមបណ្ដឹងរដ្ឋប្បវេណីសួរទៅជនជាប់ចោទ។ យើងបានផ្ញើអ៊ីម៉ែលនូវសំណួរនោះ ជូនលោកប្រធានរួចមកហើយ។ សូមអរគុណលោកប្រធាន។

[១៦:០៥:១៣]

**ប្រធានអង្គជំនុំ៖**

ផ្ញើពីពេលណា ហើយផ្ញើជាភាសាអីទៅ មកឲ្យយើង? ផ្ញើឲ្យយើងហ្នឹង ផ្ញើមកពីពេលណា ហើយផ្ញើជាភាសាអី?

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

លោកប្រធាន ខ្ញុំសូមរកមើលសិន។ សំណួរត្រូវបានផ្ញើកាលពីម្សិលមិញ ជាភាសាខ្មែរ និងជាភាសាអង់គ្លេស លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

ផ្ញើមកឲ្យយើង ឬក៏មកឲ្យអ្នកផ្សេងទៀត? មកឲ្យយើងផ្ទាល់?

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សំណួរត្រូវបានផ្ញើកាលពីថ្ងៃអង្គារជូនអង្គជំនុំជម្រះ ជាភាសាខ្មែរ និងជាភាសាអង់គ្លេស ដូចសព្វមួយដង គឺនៅម៉ោងបួន ដប់បីនាទីរសៀល គឺយើងផ្ញើជូនទៅមន្ត្រីច្បាប់ជាន់ខ្ពស់ និងអង្គជំនុំជម្រះលោកប្រធាន គឺថ្ងៃអង្គារ ម៉ោងពីរ ដប់បីនាទីរសៀល លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

ដើមបណ្ដឹងរដ្ឋប្បវេណី តើមានសំណួរអីចង់សួរទៅជនជាប់ចោទដែរឬទេ? បើមានសូមអញ្ជើញ!

[១៦:០៦:៥៥]

**លោក ឡាច គ្រី៖**

បាទ ខ្ញុំបាទសុំសួរសំណួរពីរចំណុចដែលជាសារៈសំខាន់របស់ខ្ញុំ និងប្រជាជនរបស់ខ្ញុំបាទដែលនៅភូមិពោធិ៍ចិន្ដាំហ្នឹង។ ខ្ញុំចង់សួរថា ទី១ មេដឹកនាំទាំងអស់នុ៎ង នៅក្នុងសង្គមប្រជាធិបតេយ្យហ្នឹង តើលោកដឹងថា ថ្នាក់ក្រោមលោកនេះ បាននែ៎ដឹងថា សម្លាប់ប្រជាជនដែរឬទេ? ទី១។

ហើយទី២ ខ្ញុំបាទសួរថា គោលបំណងដែលលោកឲ្យថ្នាក់ក្រោមរបស់លោកបញ្ជាឲ្យថ្នាក់ក្រោមរបស់លោកសម្លាប់ប្រជាជននុ៎ង តើគោលបំណងអ្វី ដើម្បីសម្លាប់ប្រជាជនហ្នឹង? ខ្ញុំសួរតែពីរចំណុចហ្នឹងទេ ឲ្យៗលោកឆ្លើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយលោក ឡាច គ្រី អង្គជំនុំជម្រះសូមជម្រាបជូនលោកថា សវនាការកាលពីថ្ងៃទី០៨ ខែមករា ២០១៥ បន្ទាប់ពីអង្គជំនុំជម្រះបានស្ដាប់ជនជាប់ចោទទាំងពីរនាក់ឆ្លើយបញ្ជាក់ពីការដែលពួកគាត់រក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបនឹងសំណួរ អង្គជំនុំជម្រះបានកត់សម្គាល់ថា ជនជាប់ចោទទាំងពីរនាក់ នៅតែរក្សាជំហររបស់ខ្លួនបន្តអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតបដដែល។ លើកលែងតែ និងរហូតដល់ពេលណា ដែលអង្គជំនុំជម្រះសាលាដំបូងទទួលបានព័ត៌មានជាក់ច្បាស់ផ្សេងពីជនជាប់ចោទឬពីសហមេធាវីការពារក្ដីជនជាប់ចោទ។ នៅក្នុងសវនាការថ្ងៃនោះ អង្គជំនុំជម្រះបានកំណត់ឲ្យជនជាប់ចោទ និងសហមេធាវីការពារក្ដីជនជាប់ចោទ ត្រូវមានកាតព្វកិច្ចទទួលខុសត្រូវក្នុងការជូនដំណឹងដល់អង្គជំនុំជម្រះឲ្យទាន់ពេលវេលា និងមានប្រសិទ្ធភាព ប្រសិនបើជនជាប់ចោទសម្រេចលះបង់សិទ្ធិនៅស្ងៀមមិនឆ្លើយតប ហើយយល់ព្រមឆ្លើយតបនឹងសំណួររបស់ជនជាប់ចោទ ឬភាគី។ ហើយនៅដំណាក់កាលមួយនៃកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយរហូតមកដល់ពេលនេះ អង្គជំនុំជម្រះមិនទាន់បានទទួលដំណឹងពីការផ្លាស់ប្ដូរជំហររបស់ជនជាប់ចោទទាំងពីរនាក់ ពីការសម្រេចលះបង់សិទ្ធិក្នុងការនៅស្ងៀមមិនឆ្លើយតប មកជាការយល់ព្រមឆ្លើយតបនៅឡើយទេ។ សូមលោកជ្រាប។ អង្គជំនុំជម្រះមិនអាចបង្ខំឲ្យគាត់ឆ្លើយតប នៅពេលដែលគាត់រក្សាសិទ្ធិមិនឆ្លើយតបបានទេ។ លោកយល់ទេ លោក ឡាច គ្រី?

[០៦:០៩:១៦]

**លោក ឡាច គ្រី៖**

បាទ លោកប្រធាន ខ្ញុំយល់ហើយ។

**ប្រធានអង្គជំនុំ៖**

បាទៗ ហើយឥឡូវនេះ អង្គជំនុំជម្រះសូមអរគុណលោក ឡាច គ្រី។ សវនាការស្ដាប់--

**លោក ឡាច គ្រី៖**

បាទៗ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សក្ខីកម្ម និងការថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា និងព្យសនកម្ម ដែលលោកទទួលរងក្នុងឋានៈលោកជាដើមបណ្ដឹងរដ្ឋប្បវេណី ហើយបានដល់ទីបញ្ចប់ហើយ។ ហើយសក្ខីកម្មរបស់លោក នឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្ដីនេះ។ ហើយលោក សូមលោកមានសុខភាពល្អ ជួបតែសំណាងល្អ និងបានសេចក្ដីសុខ សេចក្ដីចម្រើន ហើយលោក ឡាច គ្រី អាចសម្រាកបានហើយ។

បាទ អង្គជំនុំជម្រះក៏សូមអរគុណលោក ញ៉ែម សំណាង បុគ្គលិកអង្គភាពគាំពារសាក្សី និងអ្នកជំនាញដែលបានជួយគាំទ្រ និងរៀបជួយសម្រួល សម្របសម្រួលរៀបចំប្រព័ន្ធសោតទស្សន៍ ដល់ដំណើរការសវនាការស្ដាប់សក្ខីកម្ម ឡាច គ្រី ពីចម្ងាយ ហើយបានទទួលលទ្ធផលល្អ ហើយលោកអាចសម្រាកបានហើយ។

**លោក ញ៉ែម សំណាង៖**

បាទ អរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សវនាការនៅថ្ងៃនេះ ដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃចន្ទ ទី២៥ ខែមករា ឆ្នាំ២០១៦ ចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹកទៅ។ ហើយសវនាការនៅថ្ងៃចន្ទ ដើមសប្ដាហ៍ក្រោយនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការជាសាធារណៈស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណី ដែលមានរហស្សនាម 2-TCCP-869 ពេញមួយថ្ងៃ សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

ហើយបង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូបលោក នួន ជា និងលោក

ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ ត្រឡប់ចូលរួមសវនាការនៅថ្ងៃចន្ទ ទី២៥ ខែមករា ឆ្នាំ២០១៦ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក៕

សម្រាកចុះ!

*(សវនាការផ្អាកនៅម៉ោង ១៦:១១នាទី)*